# សន្និសីទទីក្រុងហ្សឺណែវ ស្តីពីឥណ្ឌូចិន និង បញ្ហាប្រទេសកម្ពុជាឆ្នាំ១៩៥៤

## Geneva Conference on Indochina and Problems of Cambodia in 1954

**ខង សុធារ៉ា**

**សាស្ត្រាចារ្យនៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២**

និន្នាការទូទៅនៃមតិសាធារណអន្តរជាតិ នៅដើមទសវត្សឆ្នាំ១៩៥០ បានផ្តោតអារម្មណ៍ទៅលើបញ្ហាសង្គ្រាមនៅឧបទ្វីបកូរេ និងនៅឥណ្ឌូចិន ដោយរំពឹងគិតថា វានឹងត្រូវបានគេដោះស្រាយតាមរយៈការចរចា ។ នៅកូរេ គេបានបញ្ឈប់សង្គ្រាមដ៏ឃោរឃៅមួយនាខែសីហាឆ្នាំ១៩៥៣ ដោយសារការចរចាដោយសន្តិវិធី ។ កិច្ចព្រមព្រៀងយុទ្ធសន្តិភាពនេះ បានក្លាយជាគំរូមួយ សំរាប់ជាមធ្យោបាយដោះស្រាយជម្លោះទាំងឡាយ ជាពិសេសជម្លោះនៅឥណ្ឌូចិនតែម្តង ។

ដោយឈរលើគោលការណ៍ខាងលើដើម្បីបញ្ចប់អរិភាព និងពន្លត់ភ្លើងសង្គ្រាមនោះ សន្និសីទនៃរដ្ឋមន្ត្រីការបរទេសមួយ ដែលមាន ប្រតិភូសហភាពសូវៀត សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងសាធារណរដ្ឋបារាំង បានជួបប្រជុំគ្នានៅទីក្រុងប៊ែរឡាំង(Berlin)នៃប្រទេសអាល្លឺម៉ង់ដំបូង នាខែមករាឆ្នាំ១៩៥៤ ។ ក្រោយមកនៅថ្ងៃទី ១៧កុម្ភៈ សម្រេចចេញសេចក្តីប្រកាសរួមគ្នា ថានឹងកោះប្រជុំសន្និសីទអន្តរជាតិមួយថ្នាក់រដ្ឋមន្ត្រីការបរទេស នៅទីក្រុងហ្សឺណែវ(Geneva)ប្រទេសស្វីស ក្នុងខែមេសាខាងមុខ ស្តីអំពីបញ្ហាប្រទេសកូរេ និងការបញ្ឈប់សង្គ្រាម ហើយកសាងសន្តិភាពឡើងវិញនៅឥណ្ឌូចិន ដោយគ្រោងអញ្ជើញចូលរួមនូវប្រតិភូនៃសាធារណរដ្ឋចិនប្រជាមានិត ព្រមទាំងបណ្តាប្រទេសដែលបានជាប់ទាក់ទិននឹងទស្សនៈឆ្ពោះទៅរកដំណោះស្រាយបញ្ហាសន្តិភាពនៃប្រទេសកូរេ និងឥណ្ឌូចិន ។

ដោយឡែកចំពោះប្រទេសកម្ពុជា សម្តេច នរោត្តម សីហនុ បានប្រកាសជាឧឡារិកនូវឯករាជភាព អធិបតេយ្យភាពនៃប្រទេសតាំងពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដែលជាជោគជ័យផ្តាច់ព្រ័ត្រនៃរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិរបស់ព្រះអង្គ ។ ចំណែកភ្លើងសង្គ្រាម ដែលកំពុងឆាបឆេះនៅឥណ្ឌូចិន គឺជាសង្គ្រាមតស៊ូរំដោះជាតិចេញពីរបបអាណានិគមបារាំង ចុះតើកម្ពុជាមានបញ្ហាអ្វីដែរ ដើម្បីយកទៅពិភាក្សានៅក្នុងសន្និសីទ បើខ្លួនបានទទួលឯករាជ្យពេញបរិបូរណ៍តាំងពីចុងឆ្នាំ១៩៥៣ម្ល៉េះ ។

## ១. សមាសភាពប្រតិភូ

សន្និសីទអន្តរជាតិទីក្រុងហ្សឺណែវ បានចាប់ផ្តើមបើកនៅថ្ងៃទី២៦ ខែមេសា ប៉ុន្តែនៅដំណាក់កាលដំបូង គេបានពិភាក្សាបញ្ហាទំនាស់នៃប្រទេសកូរេ ទើបតែមកដល់ថ្ងៃទី ០៨ ខែឧសភា បន្ទាប់ពីថ្ងៃដែលបន្ទាយ ឌៀន បៀន ភូដ៏ធំរបស់បារាំងនៅវៀតណាម ត្រូវដួលរលំដោយសារស្នាដៃវៀតមិញ ។ កិច្ចពិភាក្សាស្តីអំពីបញ្ហាឥណ្ឌូចិន ចាប់បើកឡើង

ដែលមានគណប្រតិភូនៃប្រទេសចំនួនប្រាំបួនចូលរួម ។ ប្រទេសធំៗខាងលោកសេរីមាន : សាធារណរដ្ឋបារាំង ដឹកនាំដោយលោក ហ្សក ប៊ីដូល(George Bidault) និងលោក ហ្សង់ សូវែល(Jean Chauvel) ក្រោយមកដឹកនាំដោយលោក ព្យែរ ម៉ង់ដេសហ្វ្រង់ (Pierre Mendès France) ដែលជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសផង សហរដ្ឋអាមេរិក[១] ដឹកនាំដោយលោក វ៉ារធឺ បេដេល ស្មីត(Water Bedell Smith) ដែលជាឧបការីរដ្ឋលេខាធិការការបរទេសអាមេរិក និងលោក យូ អេ ហ្សនសុន(U. A. Johnson) និងចក្រភពអង់គ្លេស ដឹកនាំដោយលោក អែនថូនី អេដេន (Anthony Eden)ដែលមាននាទីជាសហប្រធានសន្និសីទ ។ រីឯប្រទេសធំៗខាងកុម្មុយនីស្តមាន : សហភាពសូវៀត ដឹកនាំដោយលោក វ្យាតឆេស្លាវ ស្គ្រីយ៉ាប៊ីន ម៉ូឡូតូវ (Viatcheslav Scriabine Molotov) ដែលជាសហប្រធាន និងលោក អង់ដ្រេ ក្រូមីកូ(Andrei Gromyko) សាធារណរដ្ឋចិនប្រជាមានិត ដឹកនាំដោយលោក ជូ អេនឡាយ (Chou Enlay) និង លី កេនុង(Ly Ke Nung) ។

ភាគីសាមីចំនួនបួនប្រទេសត្រូវបានអញ្ជើញអោយចូលរួមផងដែរ គឺ ទី១- សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ឬវៀតមិញ ដឹកនាំដោយលោក ផាម វ៉ាន់ដុង(Pham Van Dong) និងឧត្តមសេនីយ៍ តា កាងប៊ូ (Ta Kang Buu) ។ ទី២- រាជាណាចក្រកម្ពុជា មានលោក ទេព ផន លោក នង គីមនី លោក សម សារី លោក សឺន សាន លោក ប៉ុក ធឿន ឧត្តមសេនីយ៍ ញ៉ឹក ជូឡុង វរសេនីយ៍ ស្រី សាម៉ន និងស៊ុត សាខន ។ ទី៣- រាជាណាចក្រឡាវ ដឹកនាំដោយលោក ភី សាណានីកន(Phoui Sananikone) និងកាំប៉ាន់ ប៉ាន់យ៉ា(Kampan Panya) និងទី៤- ប្រទេសវៀតណាមខាងត្បូង (រដ្ឋាភិបាលមហាក្សត្របៅដាយ) ដឹកនាំដោយលោក ង្វៀន កុកឌិញ(Nguyen Quoc Dinh) និងត្រាន់ វ៉ាន់ដូ(Tran Van Do) ។

ក្រៅពីនោះនៅមានគណប្រតិភូសង្កេតការណ៍ក្រៅផ្លូវការ[២] នៅក្រៅសាលសន្និសីទជាច្រើនទៀត ដូចជា ឥណ្ឌាមានលោក ក្រឹស្ណា មេនន់ (Krishna Menon) ថៃមានព្រះអង្គម្ចាស់ វ៉ាន់ វ្យាថាយ៉ាគុន(Wan Waytha yakon) កាណាដាមានលោក ឡេស្ទ័រ ភៀសុន(Lester Pearson) បន្ទាប់មកអ្នកជំនួសរូបលោក គឺ លោក ឆេស្ទ័រ រោននីង (Chester Ronning) អូស្ត្រាលីមានលោក វ្យ៉ាត(Wyatt) ។

នៅទីនោះដែរ គណប្រតិភូពីរ ដែលនាំយកទៅដោយវៀតមិញ គឺប្រតិភូឡាវឥស្សរៈ និងប្រតិភូខ្មែរវៀតមិញ ដែលតំណាងអោយរដ្ឋាភិបាលតស៊ូខ្មែរឥស្សរៈ មានលោក កែវ មុនី និងលោក ម៉ី ផូ ។ គណប្រតិភូរាជរដ្ឋាភិបាលកម្ពុជាក៏បាននាំយកទៅហ្សឺណែវផងដែរ នូវមេដឹកនាំខ្មែរឥស្សរៈមួយចំនួន ដែលបានចុះចូលជាមួយរាជរដ្ឋាភិបាល ដូចជា លោក ដាប ឈួន[៣] ។

---

[១] លោក ចាន់ ដារ៉ា ថា ប្រតិភូសហរដ្ឋអាមេរិកគ្រាន់ជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ ។

[២] តាមកំណត់ហេតុ ដែលអេដេនថ្លែងណែនាំអំពីរបៀបវារៈសន្និសីទនៅម៉ោងដំបូង ត្រង់ចំណុចទី២ថា: ការពិភាក្សានឹងប្រព្រឹត្តទៅដោយគ្មានអ្នកសង្កេតការ ។ ប្រទេសទាំងនេះបានចូលរួមចំណែកខ្លះៗ ក្នុងការសំរុះសំរួលភាគីជម្លោះ នៅខាងក្រៅសាលសន្និសីទ ។

[៣] គាត់ជាមេខ្មែរឥស្សរៈ ដែលមានឈ្មោះល្បីជាងគេនៅអាណាខេត្តភាគខាងជើងកម្ពុជា ។

# ២. ខ្លឹមសារកិច្ចចរចា

ខ្លឹមសារនៃកិច្ចចរចា គឺ"ការបញ្ឈប់សង្គ្រាម និងកសាងសន្តិភាពឡើងវិញនៅឥណ្ឌូចិន ប្រកបដោយការធានាខុសត្រូវ" ។ មុនសម័យប្រជុំបើកឡើង គណប្រតិភូប្រាំមួយ គឺ អាមេរិក អង់គ្លេស បារាំង កម្ពុជា វៀតណាម និងលាវ បានចងសម្ព័ន្ធភាពនឹងគ្នា ដោយសន្យាថា នឹងជួយគ្នាទៅវិញទៅមក ។ នៅពេលជំនុំលើកដំបូងនោះគ្រាន់តែជាឱកាសអោយគណប្រតិភូបារាំង បានថ្លែងពីបំណងចង់បំបាត់សង្គ្រាមនៅឥណ្ឌូចិន ដើម្បីនឹងបង្ហាញសុឆន្ទៈនេះដល់ពិភពលោកប៉ុណ្ណោះ ហើយផែនការគោលសំរាប់កិច្ចពិភាក្សាបញ្ចប់ជម្លោះ ក៏ត្រូវបានភាគីប្រតិភូបារាំងរៀបចំបង្ហាញមុនគេ ដែលគំរោងផែនការនោះចែកជាបីផ្នែកគឺ :

1- សំរាប់ប្រទេសវៀតណាម

- ការប្រមូលផ្តុំកងឯកភាពនិយ័តទាំងអស់ ដាក់នៅក្នុងទីតាំងប្រមូលផ្តុំ តាមការកំណត់ទុករបស់សន្និសីទយោងតាមសំណើរបស់មេបញ្ជាការកងទ័ព ។
- ការដកអាវុធពីកងកំលាំងមិនមែនជាកងទ័ព និងកងកំលាំងមិនទទួលបន្ទុកថែរក្សារបៀបរៀបរយ ។
- ការដោះលែងជាបន្ទាន់នូវអ្នកទោសសង្គ្រាម និងអ្នកជាប់ឃុំស៊ីវិល ។
- ការត្រួតពិនិត្យកិច្ចប្រតិបត្តិខព្រមព្រៀង ដោយគណកម្មការអន្តរជាតិ ។
- ការបញ្ឈប់ប្រទូស្តរាយភ្លាមបន្ទាប់ពីចុះហត្ថលេខាព្រមព្រៀង ។ ការប្រមូលផ្តុំកងទ័ព និងប្រតិបត្តិការដកអាវុធ ដែលបានចង្អុលបង្ហាញខាងលើ ចាប់ផ្តើមយ៉ាងយឺត១០ថ្ងៃ បន្ទាប់ពីការចុះហត្ថលេខាព្រមព្រៀង ។

2- សំរាប់ប្រទេសកម្ពុជា និងឡាវ

- ការដកថយ នូវរាល់កងកំលាំងនិយ័ត និងអនិយ័តវៀតមិញ ដែលបានលុកលុយប្រទេសទាំងពីរ ។
- ការដកអាវុធពីកងកំលាំងមិនមែនជាកងទ័ព និងកងកំលាំងមិនទទួលបន្ទុកថែរក្សារបៀបរៀបរយ ។
- ការដោះលែងជាបន្ទាន់នូវអ្នកទោសសង្គ្រាម និងអ្នកជាប់ឃុំស៊ីវិល ។
- ការត្រួតពិនិត្យកិច្ចប្រតិបត្តិខព្រមព្រៀង ដោយគណកម្មការអន្តរជាតិ ។

3- ការធានាកិច្ចព្រមព្រៀង ដែលបានទទួលយកដោយប្រទេសជាសមាជិកនៃសន្និសីទក្រុងហ្សឺណែវ ។ រាល់ការរំលោភបំពាន នឹងត្រូវបានដោះស្រាយដោយការសុំយោបល់ជាបន្ទាន់ ពីប្រទេសទាំងឡាយ ដែលបានចង្អុលទុកខាងលើ នៅក្នុងទស្សនៈនៃបណ្តឹងជាឯកតោភាគី ឬរួមគ្នា ក្នុងក្របខ័ណ្ឌយោគយល់គ្នា ។

បន្ទាប់មក ភាគីដទៃទៀត ក៏បានចេញសេចក្តីថ្លែងការណ៍ជុំវិញវត្ថុបំណងរបស់សន្និសីទ និងកំនត់គោលការណ៍ដោះស្រាយតាមមធ្យោបាយ និងវិធីសាស្រ្ត ដែលគេចង់បានរៀងៗខ្លួន ។ ក្នុងនោះ ក្រោយពីចែកផ្សាយនូវផែនការសំរាប់ពិភាក្សា ក៏នៅមានបទអត្ថាធិប្បាយ និងបទអន្តរាគមន៍យ៉ាងផុលផុស សំដៅការពារទស្សនៈរបស់ខ្លួន ឬបក្សពួក

ខ្លួនផងដែរ ។ ប៉ុន្តែ នៅក្នុងទិវាដំបូងនេះ មានសំណើមួយ ដែលបានលើកឡើងដោយប្រតិភូវៀតមិញ បានធ្វើអោយបរិយាកាសសន្និសីទប្រព្រឹត្តទៅយ៉ាងតឹងតែង និងតំរូវអោយមហាអំណាច លើកយកមកដោះស្រាយមុនគេ មុននឹងឈានដល់ការពិភាក្សាលើផែនការបញ្ឈប់សង្គ្រាម ។

## ឥ- បញ្ហាខ្មែរវៀតមិញ

សេចក្តីថ្លែងការណ៍មួយ ដែលប្រតិភូវៀតមិញចែកទៅគ្រប់ប្រតិភូ ធ្វើអោយបរិយាកាសសន្និសីទប្រព្រឹត្តទៅយ៉ាងតឹងតែងនោះ គឺការទាមទារអោយបណ្តាប្រទេស ដែលរួមដៃធ្វើសន្និសីទអនុញ្ញាតអោយចូលរួមការងារសន្និសីទ នូវភាគីរដ្ឋាភិបាលតស៊ូខ្មែរឥស្សរៈ ឬខ្មែរវៀតមិញរបស់លោក សឺង ង៉ុកមិញ ដែលវៀតមិញខ្លួនឯងហៅថា "ខ្មែរសេរី" និងភាគីរដ្ឋាភិបាលតស៊ូឡាវឥស្សឡារបស់ព្រះអង្គម្ចាស់ សុផានុវង្ស ។

ក្រោយពីលោក ប៊ីដូល បញ្ចប់ស័ង្កថាភ្លាម លោកស្ទិត បាននិយាយរារាំងការបញ្ចូលប្រតិភូរដ្ឋាភិបាលតស៊ូខ្មែរ និងប៉ាថេតឡាវទៅក្នុងសន្និសីទ តាមគំនិតទាមទាររបស់វៀតមិញ ។ ស្ទិត បានរំឮកពីសេចក្តីប្រកាសក្រុងប៊ែរឡាំង ដែលបានស្តែងចេញជាលទ្ធផល គឺប្រតិភូតំណាងអោយរដ្ឋធំនួនប្រាំបួន ដែលកំពុងអង្គុយប្រជុំនៅជុំវិញតុសន្និសីទនោះឯង ។

ជាបន្ទាប់លោក ជូ អេនឡាយ បានថ្លែងការណ៍គាំទ្រសំណើរបស់ភាគីវៀតមិញ ។ ប៉ុន្តែគ្រាន់តែជាពិធីការប៉ុណ្ណោះ ។ លោក ម៉ូឡូតូវ ភ្លាមនោះសំដែងការចាប់អារម្មណ៍ និងគាំទ្រយ៉ាងមុតមាំទៅលើសំណើនោះផងដែរ ។ គាត់បានយោងទៅលើខ្លឹមសារនៃសេចក្តីសម្រេចទីក្រុងប៊ែរឡាំង ដែលបានកំណត់រួចហើយថា នឹងត្រូវអញ្ជើញប្រទេសធំទាំងប្រាំគឺ សាធារណរដ្ឋបារាំង ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក សហភាពសូវៀត និងសាធារណរដ្ឋចិនប្រជាមានិត និងរដ្ឋសាមីដទៃទៀត ។ ដូច្នេះមានរដ្ឋ ដែលត្រូវបានអញ្ជើញអោយចូលរួមលើសពីប្រាំ ។ រដ្ឋទាំងនោះ គឺសុទ្ធសឹងជាភាគីសាមី ដោយសាររដ្ឋាភិបាលរបស់គេបានដឹកនាំការប្រយុទ្ធ ដើម្បីឯករាជ្យជាតិ និងសេរីភាពរបស់ខ្លួន ពួកគេបានជួយលើកកំពស់ ជីវភាពប្រជាជននៅតំបន់រំដោះផងដែរ ។ សង្គ្រាមជាតិ និងសង្គ្រាមជួយស្រោចស្រង់ជាតិនឹងបន្តទៅទៀត បើគ្មានការចូលរួមពីភាគីនៃរដ្ឋាភិបាលតស៊ូ ដែលពួកគេបានកំពុងខិតខំប្រយុទ្ធ ។ ការចូលរួមរបស់ពួកគេនឹងអាចរាយការណ៍បានល្អ នូវព្រឹត្តិការណ៍របស់ប្រទេសទាំងនេះ ហើយដែលជាវិភាគទានដល់ដំណោះស្រាយសន្តិភាពឡើងវិញនៅឥណ្ឌូចិន ។

ឆ្លៀតពេលនោះ ប៊ីដូល រំលឹកថា "កង្វល់ដ៏ធំចំបងគឺសន្តិភាព" អង្គប្រជុំមិនត្រូវលិចលង់ទៅក្នុងនីតិវិធីដ៏លំបាកបែបនេះទេ ហើយអេដេន បានព្រមានថែម និងនិយាយឡើងវិញអំពីសំណើផ្អាកជំនុំ ដែលនឹងលើកឡើងដោយស្ទិត ។

ចំណែកលោក សម សារី បានឆ្លើយតបទៅប្រតិភូកុំមុយនីស្តវៀតមិញ និងសូវៀត នូវអ្វីដែលហៅថា"ខ្មែរសេរី" លោកចោទសួរថា រដ្ឋាភិបាលតស៊ូខ្មែរសេរីកើតឡើងនៅពេលណា? បើតាមប៊ីដូលថា កងទ័ពអនិយ័តវៀតមិញទើបតែបានចាប់ផ្តើមការវាយប្រហារមកលើរាជរដ្ឋាភិបាលកម្ពុជា ពីថ្ងៃ០៣មេសាប៉ុណ្ណោះ ពោលគឺក្រោយពីមានសេចក្តីប្រកាសទីក្រុងប៊ែរឡាំងថានឹងបើកសន្និសីទនៅទីក្រុងហ្សឺណែវ ។ បើសិនជាមានរដ្ឋាភិបាលខ្មែរសេរីមែន គឺជារដ្ឋាភិបាលដែលបង្កើតឡើងសំរាប់បំពេញសេចក្តីត្រូវការនៃហេតុផលចាំបាច់មួយ ។

ស្តីអំពីទឹកដីដ៏ធំទូលាយរបស់ជាតិ ដែលត្រូវបានរំដោះដោយក្រុមនេះ ដែលបានលើកឡើង គឺពុំមែនជាការពិតទេ វាមានតែតំបន់ដែលបានកាន់កាប់ក្នុងរយៈពេលខ្លីដោយកងកំលាំងអនិយ័តវៀតមិញ នៅពេលដែលពួកគេរត់គេចវេស ហើយនៅថ្ងៃបន្ទាប់មកត្រូវភៀសខ្លួនទៅក្នុងព្រៃ ឬព្រៃភ្នំ ឬឆ្លងកាត់ព្រំដែន កាលបើកងកំលាំងរដ្ឋាភិបាលនិយ័តកម្ពុជាទៅដល់ ។ នេះហើយជាទឹកដី ដែលគេចាត់ទុកជាតំបន់រំដោះ ។ ចំពោះប្រជាជនដែលរស់នៅតំបន់រំដោះទាំងនេះ ស្ថិតក្នុងសភាពទុក្ខព្រួយ ក្រោមការរឹបជាន់ ទារពន្ធដារយ៉ាងធ្ងន់ធ្ងរ ទទួលរងការចាប់ជំរិត ការលួចប្លន់ ការសម្លាប់និងក្តីឈឺចាប់អំពីប្រព្រឹត្តិកម្មដ៏អាក្រក់របស់ពួកគេ នៅពេលណាកងកំលាំងរាជរដ្ឋាភិបាលមិនអាចការពារបាន ។

អំពីការស្រឡាញ់របស់ប្រជារាស្ត្រចំពោះខ្មែរសេរីទាំងនេះ គឺគ្មានទេ ។ ប្រជារាស្ត្របានទទូចសុំអាវុធមិនឈប់ឈរពីរាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធតបតនឹងពួកវៀតមិញ ឬបក្សព័ន្ធរបស់ពួកនេះ ។ នេះបង្ហាញថា ប្រជារាស្ត្រខ្មែរស្រឡាញ់សន្តិភាពពិត១ ។ ចំណែក "ឯករាជ្យ" ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួល"រួចហើយ"នេះ គឺតាមរយៈការចារចាយ៉ាងសាមញ្ញជាមួយបារាំង មិនមែនបានមកពីការខិតខំប្រយុទ្ធដោយវីរភាពរបស់ខ្មែរសេរីនោះទេ ។

កិច្ចព្រមព្រៀងបារាំង-ខ្មែរដោយឡែក១ពីគ្នា ស្តីពីការដាក់ផ្ទេរសមត្ថកិច្ចតាមស្ថាប័ននានានៃរាជការ ត្រូវបានគណប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ចែកជូនទៅគ្រប់ភាគីនៃសន្និសីទរួចហើយ ។ ប្រសិនបើគេឆ្លងកាត់ទឹកដីកម្ពុជា គេនឹងឃើញ ប៉ូលីសជាខ្មែរ យុត្តាធិការជាខ្មែរ និងយោធាជាខ្មែរ ។ ប្រសិនបើមានមន្ត្រីរាជការជាតិបារាំង នោះគឺបំណងដោយសេរី និងឆន្ទៈផ្ទាល់របស់កម្ពុជា ដែលចង់រក្សាទុក ។ នៅពេល គណប្រតិភូកម្ពុជាទៅប៉ារីស មិនមែនទៅសុំឯករាជ្យដូចដែលបាន ទទួលនោះទេ គឺដើម្បីកសាងទំនាក់ទំនងគ្នាជាមិត្តភាពសំរាប់បច្ចុប្បន្ន និងទៅអនាគត ។

ស្តីអំពី "ភាគីសាមី ឬ រដ្ឋសាមី" ទាំងអស់ សុទ្ធសឹងមានចំណែកនៅក្នុងសន្និសីទ ។ ភាគីសាមី ដែល សម សារី ដៅ គឺ ភាគីនៃប្រតិភូតំណាងអោយរដ្ឋ ដែលបានកំពុងចូលរួមក្នុងសន្និសីទ ហើយអ្នកនោះ គឺវៀតមិញ ១ត្រូវតែដកកងទ័ពរបស់ខ្លួនចេញ ទើបកម្ពុជាមានសន្តិភាព និងត្រូវបានស្តាបនាឡើងវិញ ដោយមិនចាំបាច់ពឹងលើអ្វីបន្ថែមច្រើនទៀតនៅក្នុងរង្វង់សន្និសីទ ។ លោកបានបញ្ជាក់ពាក្យថា "រដ្ឋសាមី" តាមគោលការណ៍ច្បាប់អន្តរជាតិសាធារណៈ គេអាចទទួលស្គាល់រដ្ឋមួយបានតាមលក្ខខណ្ឌបី :

1- ត្រូវមានទឹកដី មានព្រំដែនច្បាស់លាស់

2- ត្រូវមានកងទ័ពនិយ័ត

3- កងទ័ពនិយ័តនេះត្រូវដាក់ក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់រដ្ឋាភិបាលនិយ័តមួយ

តាមរយៈច្បាប់នេះ ការកត់សំគាល់ទៅលើអ្វី ដែលអះអាងថា "រដ្ឋាភិបាលខ្មែរសេរី" ទី១ គឺគ្មានទឹកដីអ្វីទាំងអស់ បើមានទឹកដីគឺជាទឹកដីប្រទាញប្រទង់ និងផ្អែកលើព្រឹត្តិការណ៍មិនទៀងទាត់ ដែលកម្ពុជាមិនចាត់ទុកជាទឹកដីមួយបាន ទី២ គឺគ្មានកងទ័ពនិយ័តទាល់តែសោះ ពួកគេសុទ្ធសឹងជាចោរ[៤] ដែលប្រព្រឹត្តតែការលួច ការឆក់ប្លន់ ទី៣ គឺគ្មាន

[៤] ជនជាតិខ្មែរសម័យនោះដឹងស្ទើរគ្រប់គ្នាអំពីសកម្មភាពរបស់ខ្មែរឥស្សរៈ ហើយគេតែងនិយាយគ្រប់មាត់ថា "ឥស្សរោចាក់" ដែលមានន័យថា "ឥស្សរៈចោរ" ។ មានក្រុមឥស្សរៈចំនួនតិចបំផុត ដែលបានធ្វើសកម្មភាពល្អ និងជាវិជ្ជមាន ។

ទេរដ្ឋាភិបាលខ្មែរសេរី បើមានគឺត្រូវបានគេបង្កើតឡើងចាប់ពីថ្ងៃទី ០៣ ខែមេសាប៉ុណ្ណោះ ។ រដ្ឋាភិបាលនេះមានសមាសភាព២ ដែលប្រឌិតឡើងសុទ្ធសាធដោយស្នាដៃគូសត្រូវរបស់កម្ពុជា ។ ខ្មែរឥស្សរៈទាំងនោះ គឺជាជនបរទេសទាំងទស្សនៈ និង មនោគមវិជ្ជានយោបាយ ។ ប្រជារាស្ត្រខ្មែរ មិនចេះលទ្ធិវៀតណាមនិយមទេ មិនស្រឡាញ់របបផ្តាច់ការព្រោះពួកគេជា ពុទ្ធសាសននិយម ។ គឺជាការត្រឹមត្រូវ តើអ្នកតំណាងសហភាពសូវៀត យល់ព្រមធ្វើការបង្ហាញអ្នកតំណាងប្រទេស របស់ខ្លួន ដោយជនជាតិប៉ូឡូញ ឬជនជាតិឆេកូម្នាក់បានទេ ?

ពួកខ្មែរឥស្សរៈសេរីទាំងនោះ តំណាងអោយតែបក្សពួកមួយក្តាប់តូចរបស់ពួកគេ គ្មានការបោះឆ្នោតទេ ។

នៅកម្ពុជាបានរៀបចំការបោះឆ្នោតជាទូទៅចំនួន៣លើករួចមកហើយ ប្រជារាស្ត្រក៏បានចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនអោយចូលទៅធ្វើការនៅក្នុងរដ្ឋសភាដែរ ។

ចំណែកខ្មែរឥស្សរៈសេរី ដែលមិនមែនកាន់កាប់ដោយពួកបរទេស ដោយប្លុកមួយដទៃពីកម្ពុជា និងជាអ្នកជាតិនិយម ស្រឡាញ់សន្តិភាព ឯករាជភាពពិតប្រាកដ បានធ្វើការចុះចូល និងស្ថិតនៅក្រោមរាជរដ្ឋាភិបាលនិយ័ត ។ អង្គភាពចុងក្រោយទាំងនោះដែលកម្ពុជាបានបង្ហាញរួចហើយ គឺអង្គភាពនៃទ័ពទ្រង់ចន្ទរង្សី និងសាវ៉ាងវង្ស ។ ដូច្នេះ ក្រុមដែលនៅសេសសល់ គឺជាខ្មែរមិនសេរី និងជាមនុស្សបំរើបរទេសដាច់ថ្លៃ ។

លោក ផាម វ៉ាន់ដុង បានអធិប្បាយយ៉ាងវែងអំពីសាវតាររបស់"ខ្មែរតស៊ូ" នៅថ្ងៃទី១០ឧសភាថា ក្រោយពីបារាំងវិលមកដាក់អាណានិគមវិញ នៅកម្ពុជានាខែតុលាឆ្នាំ១៩៤៥ ចលនាតស៊ូរបស់ប្រជាជនបានត្រូវបង្កើតឡើង ដោយកំណត់ការតស៊ូរើបំរាស់ចេញពីទាសកម្មនៃរបបអាណានិគម និងរាជានិយម ។ សន្និសីទជាតិរបស់អ្នកតំណាងប្រជាជនបានជួបប្រជុំគ្នានៅខែមេសាឆ្នាំ១៩៥០ និងបានជ្រើសតាំងតំណាងរបស់ប្រជាជនគ្រប់ស្រទាប់ អោយធ្វើជាគណកម្មាធិការរំដោះជាតិ និងបានប្រកាសឯករាជ្យនៃប្រទេសកម្ពុជា ។ សកម្មភាពចំបងរបស់គណកម្មាធិការនេះ បានប្រកាសអោយដឹងនូវសេរីភាពប្រជាធិបតេយ្យ(les libertés démocratiques) ។ ក្រោយមកគណកម្មាធិការរំដោះជាតិបានប្រែឈ្មោះរបស់ខ្លួនជាបន្តបន្ទាប់មកជា"រដ្ឋាភិបាលបណ្តោះអាសន្ន" ។ ក្រោមការដឹកនាំរបស់រដ្ឋាភិបាលនេះ ប្រជាជនខ្មែរ បាននាំមកនូវជោគជ័យដ៏ធំសំបើម នៅក្នុងការតស៊ូប្រឆាំងអាណានិគមបារាំង ពួកអន្តរាគមន៍អាមេរិកាំង និងរបបរាជានិយម ។

នៅក្នុងតំបន់រំដោះ អង្គការ(les organes du pouvoir)បានផ្តល់នូវរបបប្រជាធិបតេយ្យ លើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជន ។ ហេតុដូច្នោះហើយ កិត្យានុភាពនៃ"រដ្ឋាភិបាលតស៊ូ"ត្រូវបានពង្រឹង និងផ្សាយចូលទៅក្នុងតំបន់ ដែលសត្រូវកំពុងកាន់កាប់ជាបណ្តោះអាសន្ន ។

នៅថ្ងៃនោះដដែល លោកទេព ផន ឆ្លើយតបសុន្ទរកថារបស់លោក ដុង ដោយខំព្យាយាមទាញហេតុផលនៃភាពខុសគ្នារវាងចលនាខ្មែរឥស្សរៈ និងក្រុមឧទ្ទាមខ្មែរវៀតមិញ ដែលដុងប្រាថ្នាអោយគេបញ្ចូលទៅក្នុងសន្និសីទ ។ គាត់បានសរសើរចលនាខ្មែរឥស្សរៈថាជាចលនាតស៊ូមួយផ្សេង ដែលធ្វើការងារសំរាប់ឯករាជ្យខ្មែរបានយ៉ាងពេញលេញ ដោយសុទ្ធចិត្ត និងជាអ្នក "ជាតិនិយម" និង"ស្នេហាជាតិ"ពិតប្រាកដ ។ ព្រោះបានបោះបង់ចោលការតស៊ូរបស់ខ្លួន មកចុះចូល

ជាមួយរដ្ឋអំណាចស្របច្បាប់ ដែលបានទទួលឯករាជ្យពីបារាំង និងមានការគាំទ្រពីប្រជាជន ។ ចំណែក ពួកនៅសេសសល់ដទៃទៀត ក្រៅពីសហគមន៍ជាតិ និងកំពុងបន្តការប្រយុទ្ធប្រឆាំងរាជរដ្ឋាភិបាល ត្រូវបានចោទប្រកាន់ថា ជាពួកឧទ្ទាម ដែលស្មោះត្រង់នឹងបរទេស ធ្វើសកម្មភាពបំរើគុណប្រយោជន៍ នៃមនោគមវិជ្ជាមួយមិនមែនជារបស់ខ្លួន ។

នៅថ្ងៃទី១១ឧសភា ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាចេញសេចក្តីថ្លែងការណ៍មួយទៀត បញ្ជាក់លើបញ្ហា "អ្វីជាខ្មែរឥស្សរៈ" និងភាពជាអវិជ្ជមាននៃរដ្ឋាភិបាលនេះ ដូចមានខ្លឹមសារដោយសង្ខេបថា : នៅទីបញ្ចប់នៃសង្គ្រាមលោកលើកទី២ បន្ទាប់ពីការចាកចេញដំណើររបស់ជប៉ុន ដែលជាអ្នកបានប្រកាសឯករាជ្យអោយកម្ពុជា ការពិត ប្រជារាស្ត្រខ្មែរមិនទាន់បានទទួលជាឯកច្ឆ័ន្ទនូវស្ថាប័នរដ្ឋរបស់ខ្លួននៅឡើយ ។ បន្ទាប់ពីកិច្ចព្រមព្រៀងបារាំង-ខ្មែរ ថ្ងៃទី០៧មករា១៩៤៦ អំពី "របបអាណានិគមបារាំង ជាលើកទី២" មក ភាគខ្លះនៃប្រជាជនខ្មែរចាប់ផ្តើមធ្វើឧទ្ទាមកម្មប្រឆាំងនឹងរាជរដ្ឋាភិបាលដោយការចាប់កាន់អាវុធប្រយុទ្ធ ដើម្បី "ឯករាជ្យ" នៃកម្ពុជា ។ ក្រោយពីមានរាជបូជនីយកិច្ច ទាមទារឯករាជ្យជាតិ ដែលដឹកនាំដោយសម្តេច នរោត្តម សីហនុ និងការផ្ទេរជាបន្តបន្ទាប់នូវកេតនភ័ណ្ឌ ជាបុព្វសិទ្ធិនៃអធិបតេយ្យភាពរាជរដ្ឋាភិបាលមក មេពួកបះបោរទាំងនោះ បានសុំចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាម្តងមួយៗ ដូចជា :

| | |
|---|---|
| ការចុះចូលរបស់ ដាប ឈួន | ថ្ងៃទី៣០កញ្ញា១៩៥០ |
| ការចុះចូលរបស់ ពុត ឆាយ | ថ្ងៃទី០២ឧសភា១៩៥៣ |
| ការចុះចូលរបស់ អ៊ូច និង អ៊ុំ | ថ្ងៃទី១០មិថុនា១៩៥៣ |
| ការចុះចូលរបស់ ទ្រង់ ចន្ទរង្សី និង សាវ៉ាងវង្ស | ថ្ងៃទី២០កុម្ភៈ១៩៥៤ |

ការចុះចូលរបស់មេបះបោរទាំងពីរនាក់ចុងក្រោយនេះ ធ្វើអោយកម្ពុជាសម្រេចបាននូវឯកភាពជាតិមួយ ដែលមានសម្តេច សីហនុជាប្រមុខ ។ ដូច្នេះ វាពុំមានសេសសល់អ្នកបន្តការប្រយុទ្ធនៅក្រៅសហគមន៍ប្រជាជាតិខ្មែរទៀតទេ ដោយការប្រយុទ្ធនឹងប្រែក្លាយជាគ្មានកម្មវត្ថុ ប្រៀបដូចពួកចោរសមុទ្រ ឬចោរប្លន់ប្រដាប់អាវុធ ឬជាភ្នាក់ងារកញ្ចះវៀតមិញ ។ ពីព្រោះពួកវៀតមិញបានធ្វើអ្វីៗទាំងអស់ ដើម្បីផ្គត់ផ្គង់អង្គភាពខ្លះនៅខាងក្នុងប្រទេសកម្ពុជា សំរាប់ជាបង្អែកនៃបំណងចក្រពត្តិនិយមរបស់គេ ឬធានាដល់ពួកគេនូវភស្តុភារចាំបាច់ ដើម្បីការប្រយុទ្ធប្រឆាំងនឹងវត្តមានរបស់បារាំងនៅវៀតណាម ។

ចាប់តាំងពីឆ្នាំ១៩៤៦មក ពុំមានអ្នកបះបោរណាម្នាក់ បានបង្កើតរដ្ឋាភិបាលទេ ប្រសិនបើមានរដ្ឋាភិបាលមួយរដ្ឋាភិបាលនេះពិតជាបង្កើតឡើងសំរាប់ជាបុព្វហេតុចាំបាច់ ធ្វើជាបង្អែករបស់ពួកវៀតមិញនៅសន្និសីទទីក្រុងហ្សឺណែវ ។ បើរដ្ឋាភិបាលនេះមានមែន ត្រូវតែដឹងថា :

1- កន្លែងណាជាទីស្នាក់ការរបស់គេ ?

2- អ្វីជាសមាសភាពរបស់គេ ?

3- រដ្ឋណាខ្លះ ដែលបានទទួលស្គាល់ ?

4- កាលបរិច្ឆេទទទួលស្គាល់ ?

ដើម្បីពិនិត្យថារដ្ឋាភិបាលនេះមានពិតប្រាកដ កម្ពុជាប្រុងប្រៀបខ្លួនទទួលគ្រប់តំណាងរដ្ឋទាំងអស់ ដែលចង់រាយការណ៍អំពីភាពត្រឹមត្រូវនៃហេតុការណ៍ខាងលើ ។ ប៉ុន្តែ សំរាប់ពេលនេះ កម្ពុជាប្រឆាំងដាច់ខាតចំពោះការបញ្ចូលតំណាងរបស់"ខ្មែរសេរី"ទៅក្នុងសន្និសីទ ។

នៅសម័យប្រជុំលើកទី៦ គឺថ្ងៃទី១៨ឧសភា លោក ទេព ផន ថ្លែងអំពីឈ្មោះ សឺង ង៉ុកមិញ ថា ជាជនបរទេសម្នាក់ ដែលនាំមកដោយកងទ័ពវៀតមិញ ។ នៅកម្ពុជា គេមិនដែលស្គាល់គាត់ក្នុងនាមជាអ្នកតំណាងនៃរដ្ឋាភិបាលតស៊ូខ្មែរសេរីឡើយ ហើយវាគ្មានសង្គ្រាមរំដោះជាតិ និងគ្មានការប្រយុទ្ធគ្នារបស់កងទ័ពកម្ពុជាជាមួយកងទ័ពបារាំង ប្រឆាំងនឹងចលនារំដោះជាតិទាល់តែសោះ ។

លោក ស្មិតបានចាប់ផ្តើមនិយាយមុនគេ នៅពេលសម័យប្រជុំថ្ងៃ១៩ឧសភាបើកឡើង ដែលក្នុងនោះលោកបានថ្លែងដល់"រដ្ឋាភិបាលខ្មែរ"(gouvernement khmer) ថា បើតាមសក្ខីកម្មនៃវិទ្យុផ្សាយសម្លេងវៀតមិញ បាននិយាយយោងដល់ "រដ្ឋាភិបាលខ្មែរ" ជាលើកដំបូង នៅថ្ងៃទី២០ខែមីនាឆ្នាំ១៩៥៤ ។ ពីពេលមុន វិទ្យុនេះមិនបាននិយាយអំពី"គណកម្មាធិការរំដោះជាតិ"(comités de libération)សោះ ។ ការនេះបង្ហាញថា វាពិតជាកើតឡើងក្រោយសន្និសីទក្រុងប៊ែរឡាំង និងសំរាប់តំរូវការនៃហេតុផលមួយ ទើបគណកម្មការនេះបានប្រែមកជា"រដ្ឋាភិបាល" ។ គ្មានការសង្ស័យអ្វីទេ នោះគឺក្នុងគោលបំណងធ្វើជាតំណាងនៅសន្និសីទក្រុងហ្សឺណែវ ។ ដូច្នេះ រដ្ឋាភិបាលនេះ ឬគណកម្មាធិការនេះមិនតំណាងអោយកម្ពុជាទេ ហើយវាត្រូវបានបង្កើតឡើង ដើម្បីជាឧបករណ៍បណ្តោះអាសន្នរបស់រដ្ឋាភិបាលស្របច្បាប់មួយ ។

បន្ទាប់មក ដុង លើកឡើងអំពីសមិទ្ធិផលបដិវត្តន៍របស់រដ្ឋាភិបាលតស៊ូជាថ្មីម្តងទៀតថា បានរំដោះទឹកដីខេត្តសៀមរាបនៅខែសីហាឆ្នាំ១៩៤៦ រំដោះទឹកដីភូមិភាគអគ្នេយ៍នៅឆ្នាំ១៩៤៨ រំដោះទឹកដីភូមិភាគនិរតីនៅចុងឆ្នាំ១៩៤៨ រំដោះទឹកដីភូមិភាគឥសាន និងពាយព្យនៅឆ្នាំ១៩៤៩ ។ មូលដ្ឋានបង្អែក ត្រូវបានរៀបចំទូលំទូលាយចាប់ពីតំបន់ជាប់ព្រំប្រទល់ដែន វៀតណាមដល់ទល់ដែនថៃ ដែលគ្របដណ្តប់លើផ្ទៃដី ៤៨000 គីឡូម៉ែត្រការេ លាតសន្ធឹងលើទឹកដីខេត្តកំពត កំពង់ចាម កំពង់ស្ពឺ និងពោធិសាត់ ។ នៅក្នុងតំបន់រំដោះ រដ្ឋាភិបាលប្រជាធិបតេយ្យមួយ ត្រូវបានរៀបចំឡើងចាប់ពីថ្នាក់ភូមិ ស្រុក រហូតដល់ខេត្ត ។ នៅថ្ងៃទី១៩មេសាឆ្នាំ១៩៥0 សន្និសីទជាតិ មានប្រតិភូច្រើនជាង២00នាក់ចូលរួម បានបោះឆ្នោតជ្រើសតាំងគណកម្មាធិការរំដោះជាតិសំរាប់ប្រទេសទាំងមូល ។ គណកម្មការនេះហើយបានក្លាយជា"រដ្ឋាភិបាលតស៊ូ" ដែលមាន លោក សឺង ង៉ុកមិញជាប្រធាន និងជាអ្នកស្នេហាជាតិកំពូល ដែលគេស្គាល់ច្បាស់នៅកម្ពុជា រួមជាមួយនិស្សិត និងបញ្ញវន្តខ្មែរនៅស្រុកបារាំង ។ នៅថ្ងៃទី១៩មិថុនា១៩៥0 ឯករាជ្យត្រូវបានប្រកាស "ប្រជាជាតិខ្មែរបានប្រកាសខ្លួនឯង នូវសិទ្ធិសេរីភាព និងឯករាជភាព ។ ខ្មែរសេរីត្រូវបានបង្កើតឡើង ប្រជាជាតិទាំងអស់សម្រេចចិត្ត ចូលទៅក្នុងជួរកងកម្លាំងប្រកបដោយសីលធម៌ក្នុងការរស់នៅ ដើម្បីកសាងឯករាជ្យ និងសេរីភាព" ។

ភ្លាមនោះដែរ ផនបានឆ្លើយតបការពិពណ៌នារបស់ដុង ថា ទឹកដីរំដោះទំហំ ៤៨000គីឡូម៉ែត្រការ៉េ មិនមែនជាការពិត ។ តំបន់ដែលពួកនេះជ្រៀតចូលមានគិរិត និងប្រទាញប្រទង់ ពីព្រោះកងឯកភាពអនិយ័តទាំងនេះ រស់នៅដោយភៀសខ្លួន ពួកគេត្រូវចល័តកំលាំងចូលទៅតំបន់ព្រៃជ្រៅ នៅពេលណាកងកំលាំងរៀបរយនៃរាជរដ្ឋាភិបាលលេចឡើង គេមិនអាចចាត់ទុកការកាន់កាប់បែបនេះ ថាជាតំបន់រំដោះបានឡើយ ។

ខេត្តសៀមរាប មិនមែនជាតំបន់រំដោះ ដូចលោកដុងអះអាងទេ គឺជាតំបន់ស្វ័យតរបស់សម្តេច សីហនុ ដែលបង្កើតឡើងនៅថ្ងៃទី៣០សីហា១៩៤៩ ក្រោយពីមានកិច្ចព្រមព្រៀងបារាំង-ខ្មែរ ហើយខេត្តបាត់ដំបងក៏ដាក់ស្វ័យតដែរ នៅថ្ងៃទី២៩ខែធ្នូ១៩៥២ មិនមែនជាតំបន់ធ្វើសកម្មភាពរបស់"ខ្មែរសេរី"នោះទេ ។

ចំណែកកូដកម្មតាមសាលារៀនមិនមែនមានឫសគល់ពីនយោបាយទេ គឺទាក់ទងរឿងមធ្យមភាគនៃការសិក្សាដែលត្រូវឆ្លងកាត់ការឡើងថ្នាក់ ។ កូដកម្មរបស់កម្មករចំការកៅស៊ូ ដែលភាគច្រើនជាជនជាតិតុងកឹង បានកើតឡើងក្រោយពីមានការជ្រៀតចូលទៅញុះញង់របស់ក្រុមវៀតមិញ ។ ឥឡូវនេះ ត្រូវបានបញ្ចប់ក្រោយពីរាជរដ្ឋាភិបាលចាត់វិធានការណ៍ដោះស្រាយ ។

អំពីការបោះឆ្នោតសំរាប់"គណកម្មាធិការរំដោះ" ដែលមានចំណែករបស់អ្នកតំណាងប្រជាជន២០០នាក់ មិនអាចចាត់ទុកថាមានលក្ខណប្រជាធិបតេយ្យសេរី ដូចការបោះឆ្នោតជ្រើសតាំងសមាជិកសភាជាតិ ដែលបានធ្វើ(ចំនួន៣លើក)ជាទូទៅនៅទូទាំងប្រទេសរួចមកហើយនោះទេ ។

ការពិត ក្រុមចលនាឥស្សរៈខ្មែរឥស្សរៈ ដែលដឹកនាំដោយសឺង ង៉ុកមិញ បានរួបរួមជាមួយវៀតមិញដែលតំណាងដោយហ្វាង ទុង ប្រុងប្រៀបបញ្ជូនកងទ័ពប្រយុទ្ធចំនួនពីរកងពលមកកម្ពុជា ដើម្បីបង្កើតតំបន់សេរីនៅបាត់ដំបង និងសៀមរាបដាក់នៅក្រោមការត្រួតពិនិត្យរបស់រណសិរ្សរួបរួមជាតិឥណ្ឌូចិន ។ ប៉ុន្តែ ផែនការនេះត្រូវបានលោកជូ ដែលនៅពេលនោះលោកនៅហ្សឺណែវ បានរារាំងតាំងពីដំបូង ដោយព្រមានថា ទង្វើបែបនេះជាការបំផ្លាញលទ្ធផលសន្និសីទ ។

ក្រោយពីសម័យប្រជុំត្រូវបានផ្អាក នៅថ្ងៃទី២០ឧសភា វេលាម៉ោង ១០(ម៉ោងសកល) ជូ អេនឡាយ បានទៅជួបអេដេន នៅឯគេហដ្ឋាន ។ នៅក្នុងជំនួបនោះលោក ជូ បានយល់ព្រមលើការ"មិនបញ្ចូលបេក្ខភាពប្រតិភូប៉ាថេតឡាវ និងខ្មែរឥស្សរៈ" ដែលត្រូវបានគេស្នើអោយចូលរួមក្នុងកំលុងពេលសម័យប្រជុំលើកទី១ ស្តីពី ឥណ្ឌូចិន ។ ការបំបាត់សម្លេងរបស់ភាគីទាំងពីរនេះ តាមលោកជូថា ជាមធ្យោបាយដោះស្រាយចំពោះលក្ខខណ្ឌផ្អាកសង្គ្រាមជាយថាហេតុ ព្រមទាំងបើកផ្លូវសំរាប់ការពិភាក្សាលើសំណើរបស់សហភាពសូវៀត ដែលស្នើអោយមានការបង្កើតគណកម្មការត្រួតពិនិត្យមួយនៃបណ្តាប្រទេសអព្យាក្រឹត្យ ដើម្បីជួយសំរួលកិច្ចការរបស់ភាគីជម្លោះទាំងអស់ ដែលបានព្រមព្រៀងគ្នាលើបញ្ហាបញ្ឈប់ប្រទូស្តរាយយោធា ។

ប៉ុន្តែ កង្វល់ដ៏ធំរបស់ជូ បានកើតមានតាំងពីមុនពេលបើកសន្និសីទ ។ ដោយសារកាត់បានឮសេចក្តីប្រកាសពត៌មានតាមវិទ្យុ និងទូរទស្សន៍របស់ ហ្សន ហ្វូស្ទឺរ ឌុល(John Foster Dulles) ដែលបានព្រួយបារម្ភចំពោះការក្តោបយកឥណ្ឌូចិនរបស់ពួកកុំមុយនីស្ត តាមរយៈសន្និសីទក្រុងហ្សឺណែវ ហើយលោកក៏មិន ភ្លេចចំពោះការកសាងលក្ខណៈសម្បត្តិនានា ដើម្បីធ្វើសកម្មភាពរួម ទប់ទល់នឹងហេតុការណ៍នោះដែរ ។ ម្យ៉ាងទៀត ដ្វាយ អាយសិនហោវើរ(Dwight Eisenhower) ក៏បានបញ្ជាក់ជាញឹកញាប់ផងដែរថា លោកមុខជា នឹងធ្វើសកម្មភាពខាងយោធានៅឥណ្ឌូចិន ដោយមិនចាំបាច់មានការគាំទ្រពីសភាតំណាងរាស្ត្រនោះឡើយ ។ ម្យ៉ាងទៀត អាមេរិកកំពុងពិចារណាផែនការធ្វើអន្តរាគមន៍នៅឥណ្ឌូចិនតាមសំណើរបស់បារាំង ។ ប្រការទាំងនេះហើយ បានជំរុញអោយជូ ខ្លាចសហរដ្ឋអាមេរិកប្រើប្រាស់ការចាប់អារម្មណ៍របស់អន្តរជាតិទៅលើការចរចានៅហ្សឺណែវ ទៅជាការលបលួចពង្រីង និង បញ្ចូលមូលដ្ឋានសឹករបស់ខ្លួននៅ

ឥណ្ឌូចិន ។ ហេតុដូច្នេះ គាត់ចាំបាច់ត្រូវតែប្រញាប់ធ្វើសម្បទាន ដើម្បីជំរុញល្បឿនចរចាឱ្យឆាប់ឈានដល់ទីបញ្ចប់ ។

## ខ- ផែនការបញ្ចប់សង្គ្រាម និងកសាងសន្តិភាព

ផែនការនេះមានការទាក់ទិននឹងដំណោះស្រាយ : ការបញ្ឈប់ប្រទូស្តរាយយោធា ការដកថយនៃកងកំលាំងនិយ័ត និងអនិយ័តវៀតមិញ ការដោះលែងអ្នកទោសសង្គ្រាម និងអ្នកជាប់ឃុំស៊ីវិល បញ្ហាទាក់ទងចំពោះការនាំចូលកងទ័ព និងសំភារៈសឹកថ្មីៗពីបរទេសទៅក្នុងប្រទេសទាំងបី បញ្ហាគណកម្មការត្រួតពិនិត្យអន្តរជាតិលើការប្រតិបត្តិកិច្ចព្រមព្រៀង ការបោះឆ្នោតជាទូទៅក្រោយពីបញ្ចប់សង្គ្រាម ការធានាកិច្ចព្រមព្រៀង ។

### ខ.១- ការបញ្ឈប់ប្រទូស្តរាយយោធា

នេះគឺជាខសំខាន់បំផុតសំរាប់រាល់ដំណោះស្រាយនៃសង្គ្រាម ប៊ីដូលជាអ្នកបានលើកវាឡើងដំបូងគេ តាមរយៈសេចក្តីថ្លែងការណ៍អំពីគំរោងដំណោះស្រាយសន្តិភាពនៅទិវា ០៨ ឧសភា ។ ជាបន្តបន្ទាប់មក ប្រតិភូវៀតមិញ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងប្រតិភូរាជរដ្ឋាភិបាលឡាវ ក៏បានលើកសំណើបទឈប់បាញ់គ្នានេះ នៅថ្ងៃទី១០ឧសភាជាមួយគ្នា ប៉ុន្តែ មធ្យោបាយសំរាប់ឈានទៅកាន់ទីដៅរបស់គេមានលក្ខណៈប្លែកៗពីគ្នាបន្តិច ដូចជា :

បារាំង ចង់អោយការបញ្ឈប់ប្រទូស្តរាយយោធាចាប់អនុវត្តភ្លាមបន្ទាប់ពីការចុះហត្ថលេខាព្រមព្រៀង ។

វៀតមិញ ចង់អោយមានបទឈប់បាញ់គ្នាជាទូទៅក្នុងពេលតែមួយនៅឥណ្ឌូចិន ដោយភាគីកំពុងច្បាំងគ្នាទាំងអស់ ដែលមានទាំងទ័ពជើងគោក ទឹក(សមុទ្ទ) និងអាកាស ដើម្បីជាការពង្រឹងយុទ្ធសន្តិភាព ។

កម្ពុជា ចង់អោយពិភាក្សាការបញ្ឈប់ប្រទូស្តរាយយោធាមុននឹងគេលើកយកបញ្ហាដទៃទៀតមកពិភាក្សា ។

ចំនែកឡាវមិនបានចែងពីមាត្រាបទឈប់បាញ់អ្វីទេ ប៉ុន្តែថ្លែងពីបំណងបញ្ឈប់ការច្បាំងគ្នា ។

លោក ផន បានទាមទារយ៉ាងមាំម្តងទៀតនៅថ្ងៃទី១៧ឧសភា អោយសន្និសីទពិនិត្យសំណើបទឈប់បាញ់គ្នាមុនការជជែកអំពីបញ្ហាផ្សេងៗទៀត ហើយពេលនោះអង្គសន្និសីទក៏បានយល់ស្របចំពោះសំណើនេះដែរ ។

ក្រោយមកនៅថ្ងៃ២៩ឧសភា លោក អេដេន បានលើកឡើងអំពីការសិក្សាបទឈប់បាញ់គ្នាក្នុងពេលតែមួយ ។

### ខ.២- អំពីការដកកងទ័ពវៀតមិញ

ភាគីរាជរដ្ឋាភិបាលកម្ពុជា ធ្វើការទាមទារដាច់អហង្ការអោយវៀតមិញ ដករាល់កងឯកភាពនិយ័ត និងអនិយ័តរបស់ខ្លួនចេញពីកម្ពុជា ក្នុងអាការៈធ្វើពើចំពោះវត្តមានកងទ័ពបារាំងជាច្រើនវរសេនាតូច ហើយថែមទាំងអះអាងថា បើវៀតមិញព្រមដកទ័ពចេញ កម្ពុជានឹងរកឃើញសន្តិភាពដោយស្វ័យប្រវត្តិ ។

នៅថ្ងៃទី១៤ឧសភា លោក សឺន សានបានថ្លែងអំពីសុឆន្ទៈរបស់ប្រជារាស្ត្រខ្មែរ ប្រឆាំងនឹងវត្តមានរបស់វៀតមិញនៅកម្ពុជា ព្រមទាំងឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ប្រតិភូវៀតមិញ ដែលថ្លែងកាលពីថ្ងៃទី១០ឧសភា ។ នៅត្រង់ចំណុចទី៦ដល់ទី៨នៃបទអត្ថាធិប្បាយនេះមានខ្លឹមសារថា : កម្ពុជាគ្មានគោលបំណងធ្វើការចោទប្រកាន់ប្រឆាំងនឹងមនុស្ស ដែលបានសហការជាមួយបារាំងនោះទេ ។ វាគ្មានទាល់តែសោះនូវអ្នកទោសបារាំងសេស ។ ផ្ទុយទៅវិញវាមានអ្នកទោសសង្គ្រាមវៀតមិញ ហើយត្រូវដាក់សំរាប់ដូរគ្នា ក្នុងករណីដែលចោរកងទ័ពវៀតមិញដកចេញពីកម្ពុជា

ទាំងស្រុង ។ កម្ពុជាសុំអោយដកកងទ័ពសុទ្ធសាធ និងសាមញ្ញរបស់ពួកឈ្លានពានវៀតមិញ ។ កម្ពុជាសុំអោយសន្និសីទសម្រេចយកយោបល់របស់ខ្មែរ ។

ចំណែកមហាអំណាចក៏ផុលផុសក្នុងការស្វែងរកដំណោះស្រាយរួមដែរ ដែលក្នុងបញ្ហានេះអ្នកដែលខ្វល់ខ្វាយជាងគេ គឺលោក ជូ អេនឡាយ ។ បន្ទាប់ពីគាត់ជួបជាមួយអេដេនរួចហើយ នៅព្រឹកថ្ងៃ១៧ឧសភា ក្នុងជំនួបជាមួយប៊ីដូល គាត់បានអោយដឹងថា "វៀតមិញត្រូវតែដកចេញពីប្រទេសឡាវ និងកម្ពុជា" ។

ទោះជាយ៉ាងនេះក៏ដោយ ក៏នៅថ្ងៃទី១៨ឧសភាលោក ផននៅតែបន្តថ្លែងថា វាគ្មានកងទ័ពកម្ពុជា ដែលកំពុងប្រយុទ្ធជាមួយកងទ័ពបារាំង ប្រឆាំងនឹងចលនារំដោះជាតិទេ ហើយវាគ្មានកងទ័ពបារាំងនៅកម្ពុជាទាល់តែសោះ ។ ប៉ុន្តែវាមានកងទ័ពវៀតមិញ កំពុងប្រយុទ្ធជាមួយកងទ័ពជាតិនៃប្រជាជនកម្ពុជា ។ ក្នុងការឆ្លើយតបចំពោះប្រតិភូចិន ផនថ្លែងថា គ្មានសង្គ្រាមរំដោះជាតិទេ ពីព្រោះឯករាជ្យកម្ពុជាបានទទួលហើយ ។ ប្រតិភូចិននិយាយអំពីការដកកងទ័ពវៀតមិញនៅកម្ពុជា ហាក់បីដូចជា ចង់និយាយថាគ្មានកងទ័ពវៀតមិញទេ ដែលនេះជាការនិយាយអះអាងផ្ទុយពីសេចក្តីថ្លែងការណ៍របស់គណៈប្រតិភូវៀតមិញខ្លួនឯង ។ បញ្ហាកម្ពុជាផ្សេងពីបញ្ហាវៀតណាមតាមធម្មជាតិរបស់ខ្លួន ។ វិសេសភាពនៃស្ថានការណ៍របស់កម្ពុជា មានម្យ៉ាងក្នុងលក្ខណៈមិនអាចប្រកែកបាននៃការលុកលុយរបស់ពួកវៀតមិញលើទឹកដីរបស់ខ្លួន ហើយម្យ៉ាងទៀត នៅក្នុងភាពងាយស្រួលនៃបញ្ហាដែលបានចោទ :

1- លក្ខណៈមិនអាចប្រកែកបាននៃការលុកលុយបរទេស

កងឯកភាពដែលធ្វើអោយចលាចលនៅកម្ពុជា មិនមែនជាប្រជាជនកម្ពុជាខ្លួនឯងនោះទេ ។ ពួកឧទ្ទាមខ្មែរដែលប្រយុទ្ធដើម្បីឧត្តមគតិសន្តិភាព និងឯករាជ្យប្រទេសបានចុះចូលក្រោមរាជរដ្ឋាភិបាលកម្ពុជារួចហើយ [៥] ។ បច្ចុប្បន្នកងទ័ព ដែលសាបព្រោះភាពច្របូកច្របល់នៅក្នុងប្រទេស គឺកងទ័ពវៀតមិញ ដែលបណ្តុះបណ្តាលកំលាំងប្រដាប់អាវុធ

---

[៥] ក្រុមខ្មែរឥស្សរៈសេរីដ៏សំខាន់មួយទៀត ដែលមិនបានចុះចូលក្រោមរាជរដ្ឋាភិបាលសម្តេច សីហនុ គឺដឹកនាំដោយសឺង ង៉ុកថាញ់ ដែលជាអតីតនាយករដ្ឋមន្ត្រី បន្ទុបដោយយោធាជប៉ុន ។ ក្រុមនេះទើបនឹងបង្កើតនៅថ្ងៃទី ០៩កុម្ភៈ១៩៥២ ក្នុងតំបន់ភាគខាងជើងនៃប្រទេសជាប់ព្រំដែនខ្មែរ-ថៃក្នុងភូមិសាស្ត្រខេត្តសៀមរាប ។ ជនសំខាន់ៗមួយចំនួនទៀតមាន កែវ តក់ អៀ ស៊ីចូវ និងក្រោយមកមានហុង ឈុន ដែលធ្លាប់ជាបក្សពួករបស់សាវ៉ាងវង្ស ។ ថាញ់ គឺជាមនុស្សម្នាក់មានប្រជាប្រិយភាពគ្រាន់បើនៅក្នុងចំណោមសមាជិកគណបក្សប្រជាធិបតេយ្យ និងលើសពីគេនៅក្នុងក្រុមតស៊ូរបស់គាត់ ។ ប៉ុន្តែ កេរ្តិ៍ឈ្មោះមិនល្អមួយដែលផ្សាយចេញពីខេត្តបាត់ដំបងដោយសារ កូនចៅរបស់គាត់តម្រូវអោយភូមិនិមួយៗ ដែលពួកគេចុះចូលទៅដល់ផ្តល់ប្រាក់អោយគេជាមធ្យមពី៥000ទៅ១0000 រៀល ។ នេះជាការកំហិតទារពន្ធដ៏ខ្ពស់មួយ ដែលគ្មានក្រុមខ្មែរឥស្សរៈណាមួយធ្លាប់ទារដល់កំរិតនោះឡើយ ។ នៅថ្ងៃទី២៧វិច្ឆិកា ១៩៥២ ថាញ់ បានកោះប្រជុំមួយ ក្នុងការព្យាយាមអោយគេទទួលគាត់ជាប្រធានកំពូលរបស់ចលនាខ្មែរឥស្សរៈ ។ ការប្រជុំនោះមិនបានធ្វើអោយគាត់សម្រេចតាមបំណងឡើយ ។ អ្នកតំណាងនៃក្រុមឥស្សរៈតូចៗ ដែលដឹកនាំដោយ ពុត ឆាយ ទ្រង់ ច័ន្ទរង្សី និងកែវ តក់ ព្រមទទួលស្គាល់គាត់ថាជាប្រធានកំពូលរបស់រណសិរ្សឥស្សរៈ ប៉ុន្តែ លាវ កែវមុនី ដែលជាតំណាងអោយសៀវ ហេងខាងខ្មែរវៀតមិញនៅពេលនោះ បានព្យាយាមអោយគេយកសឺង ង៉ុកមិញជាប្រធានកំពូលវិញ ។ រហូតដល់ឆ្នាំ១៩៥៤ ចលនារបស់គាត់នៅក្រិនដដែល ហើយក្រោយពីសន្និសីទក្រុមរបស់គាត់បានទទួលជំនួយពីអាមេរិកតាមរយៈនាយអគ្គប៉ូលីសថៃ ប៉ាវ ស៊ីយ៉ាណន និងសេអ៊ីអា ។

នៃប្រជាជនកម្ពុជាភាគតិច ដែលត្រូវបានបោះបង់ចោលក្រៅសហគមន៍ដោយមតិប្រជាជនទាំងអស់ ។ ពួកវៀតមិញ គឺជាពួកបរទេសនៅកម្ពុជាតាមសញ្ជាតិ និងតាមមនោគមវិជ្ជារបស់ខ្លួន ។ ដំបូងពួកវៀតមិញ តាមទស្សនៈជាតិ គឺពួកវៀតណាម ជាបច្ឆាជន(កូនចៅ)នៃពួក"វៀត" ដែលកើតចេញពីយួននៃរដ្ឋវ៉ាស៊ីនៅប្រទេសចិនភាគខាងត្បូង ហើយបានធ្វើនិរប្រវេសន៍បន្តិចម្តងៗឆ្ពោះទៅទិសខាងត្បូងនៃឥណ្ឌូចិន ។ អារ្យធម៌របស់គេមានដើមកំណើតពីចិន ចំណែកឯប្រជាជនកម្ពុជាមានដើមកំណើតពីអារ្យធម៌ហិណ្ឌូ ។

តាមទស្សនៈមនោគមវិជ្ជា "ពួកវៀតមិញ" គឺផ្សេងពីគ្នាយ៉ាងច្បាស់ក្រឡែតពីប្រជាជនកម្ពុជា ដែលស្រឡាញ់របបរាជានិយម និងកាន់គោរពព្រះពុទ្ធសាសនា គឺជារបប និងសាសនាដែលផ្ទុយគ្នានឹងលទ្ធិកុំមុយនីស្ត ។

2- បញ្ហាកម្ពុជា គឺជាចរិតលក្ខណៈសាមញ្ញរបស់ខ្លួន

បញ្ហាជាពិសេស គឺបទបញ្ហាយោធា ។ គេត្រូវចាប់ផ្តើមដកកងទ័ពវៀតមិញ ដើម្បីកម្ពុជារកឃើញសន្តិភាព និងសន្តិសុខ ។ រដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជា ប្រកាសចាប់តាំងពីឆ្នាំ១៩៤៧[៦] ដែលយល់ព្រមដោយប្រជាជនទាំងអស់ ។ វាគ្មានការកែប្រែរបប ដែលកើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋនេះទេ ។

ការដកកងកំលាំងប្រឆាំងមិនបង្ហាញការលំបាកទេ ។ នៅលើទឹកដីកម្ពុជា មានតែកងខេមរៈភូមិន្ទ និងកងទ័ពវៀតមិញនិយ័ត និងអនិយ័តតែប៉ុណ្ណោះ ។ ចំណែកឯកងកំលាំងបារាំងបានដកចេញរួចហើយ[៧] ដោយអនុវត្តតាមកិច្ចព្រមព្រៀងយោធាបារាំង-ខ្មែរ ថ្ងៃទី១៧តុលា១៩៥៣ ។ ផ្ទុយពីអ្វី ដែលមាននៅវៀតណាម គឺការប្រឈមមុខរវាងកងទ័ពបរទេស និងកងទ័ពជាតិ ។ ការដកកងទ័ពបរទេស វានឹងដោះស្រាយបាននូវបញ្ហាពីរ គឺបញ្ហានយោបាយ និងយោធា តាមគោលការណ៍ជាសារវន្តនៃច្បាប់អន្តរជាតិ ។

ទាក់ទិននឹងតំបន់ដែលរុករានដោយកងទ័ពវៀតមិញ តំបន់ទាំងនេះមិនសូវសំខាន់ ហើយស្ថិតនៅឆ្ងាយពីមូលដ្ឋានរបស់ពួកគេ ដែលបានប្រមូលផ្តុំ ជាពិសេសនៅខាងជើងប្រទេសតុងកឹង ក្នុងតំបន់ជិតខាងក្បែរព្រំប្រទល់ដែនចិន ។ វាជាការសមហេតុផលណាស់ គេត្រូវតែបញ្ចប់ការវាតទីរបស់ពួកវៀតមិញ ដែលពុំឃើញមានយុត្តិកម្មសោះនៅលើទឹកដីកម្ពុជា ។

មកដល់ថ្ងៃទី១៩ឧសភាលោក ផននៅតែអធិប្បាយទៀតអំពីវត្តមាននៃកងទ័ពវៀតមិញនៅកម្ពុជា និងបន្តទាមទារអោយពួកនេះដកថយ ។

---

[៦] ជាការពិតសម្តេច នរោត្តម សីហនុគ្មានបំណងអោយមានរដ្ឋធម្មនុញ្ញសំរាប់ប្រទេសនោះទេ ។ ប៉ុន្តែ ដោយមិនខ្វល់ពីការមិនសព្វព្រះទ័យរបស់ព្រះមហាក្សត្រ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ក្នុងនាមជាប្រធានគណបក្សប្រជាធិបតេយ្យនៅពេលនោះ ទ្រង់បានសម្រេចចិត្តថាត្រូវតែបង្កើតរដ្ឋធម្មនុញ្ញមួយសំរាប់ប្រជារាស្ត្រខ្មែរ ។ ទោះជាយ៉ាងណារដ្ឋធម្មនុញ្ញនេះ ក៏មិនបានដាក់កំណត់ព្រំដែននៃអំណាចរបស់ព្រះមហាក្សត្រដែរ ។ យោងលើ បទសម្ភាសជាមួយសម្តេច សឺន សាននៅភ្នំពេញ ព្រឹកថ្ងៃទី២៤មិថុនា ១៩៩៨ ។

[៧] គណប្រតិភូខ្មែរនិយាយច្រំដែលៗថាគ្មានកងទ័ពបារាំងនៅលើទឹកដីរបស់ខ្លួន ការពិតនៅតំបន់ខាងកើតនៃជ្រលងទន្លេមេគង្គមានកងទ័ពបារាំងជាច្រើនវរសេនាតូច ដែលតាមរយៈជំនួបក្រៅផ្លូវការជាមួយ ស្មិតនៅថ្ងៃ១១ឧសភា លោក ផនថ្លែងថា គាត់មានគោលដៅគាបសង្កត់អោយកងទ័ពវៀតមិញឈ្លានពាន និងកងទ័ពបារាំងដែលរាជរដ្ឋាភិបាលហៅអោយជួយច្បាំង ដកចេញពីកម្ពុជាបាន ។

មកដល់ថ្ងៃទី២៩ឧសភា ប្រតិភូអង់គ្លេសបានទទួលយកចំនុចដូចគ្នា នៃការចាប់ផ្តើមសំរាប់តំណាងយោធា និង ចំណាយពេលសិក្សាជុំវិញបទឈប់បាញ់ និងតំបន់ប្រមូលផ្តុំនានា ដែលនឹងធ្វើតែនៅប្រទេសវៀតណាម ។

ក្នុងកិច្ចសម្ភាសមួយជាមួយអ្នកកាសែតនៅថ្ងៃទី៩ឧសភា សម សារីនៅតែអះអាងថា នៅកម្ពុជាគ្មានកងទ័ព បារាំងទេ ប៉ុន្តែមានកងទ័ពខ្មែរ ដែលរៀបចំក្របខ័ណ្ឌរបស់ខ្លួនដោយអ្នកបច្ចេកទេសបារាំង ដែលរាជរដ្ឋាភិបាលភ្នំពេញ ប្រាថ្នាចង់បានការគាំទ្រជាបណ្តោះអាសន្ន ។ បញ្ហានេះបានធូរស្រាលឡើងវិញ នៅពេលដែលលោកជូ ជួបសន្ទនាជាមួយ អេដេន និងប៊ីដូលនៅទីក្រុងបើនថ្ងៃទី១៦និងព្រឹកថ្ងៃទី១៧មិថុនា ថា "វៀតមិញត្រូវតែដកកងទ័ពខ្លួនចេញពីឡាវ និងពី កម្ពុជា" ។ នៅល្ងាចថ្ងៃដដែលនេះ លោកផន បានសំណូមពរអោយសហសេវិករបស់ខ្លួន គឺប្រតិភូប្រទេសឡាវ និង វៀតណាមយល់ព្រមឯកភាពលើសំណើរបស់លោក ដែលបានដាក់ជូនសន្និសីទកាលពីថ្ងៃទី១២ឧសភា ហើយគាត់ប្តេជ្ញា ទទួលជួបចរចាជាមួយអគ្គសេនាធិការវៀតមិញ តែក្នុងលក្ខខណ្ឌនៃបញ្ហាដកកងទ័ពប៉ុណ្ណោះ ។ ម្យ៉ាងទៀត កងទ័ព វៀតមិញ ត្រូវតែប្រមូលផ្តុំនៅប្រទេសវៀតណាម ក្នុងតំបន់ស្ថិតក្រោមការត្រួតពិនិត្យវៀតមិញ ។ ចំណែកឯកងទ័ព មិនរៀបរយ និងពួករត់ចោលជួររបស់ផ្នែកវៀតមិញ ត្រូវតែបញ្ជូនទៅប្រទេសដើមរបស់ខ្លួនវិញ ។

មកដល់ទិវា១៨មិថុនា លោក ផន បានដាក់ផែនការដំណោះស្រាយចំនួន៦ចំណុច ដែលក្នុងនោះមានទាក់ទិន នៅត្រង់ចំណុចទី១ និងទី២ ។

ទី១- ការពិភាក្សាលើបទឈប់បាញ់ព្រមគ្នានៅប្រទេសឡាវ និងកម្ពុជាព្រមទាំងវៀតណាមផងដែរ ។ គឺ ចំណុចនិមួយៗស្របគ្នានឹងសំណើរបស់ប្រតិភូកម្ពុជា ។ វានឹងគ្មានតំបន់ប្រមូលផ្តុំកងទ័ពនៅលើទឹកដីកម្ពុជាឡើយ ។ ការ ចាប់ផ្តើមបទឈប់បាញ់គ្នាមួយ ត្រូវធ្វើជាបន្ទាន់ស្របពេលគ្នានឹងការដកកងទ័ពបរទេសនិយ័ត និងអនិយ័ត ហើយចម្លើយ គឺថា ក្រោយពេលកងកំលាំងវៀតមិញដកថយអស់ កម្ពុជានឹងគ្មានទៀតទេនូវវត្តមាននៃកងទ័ពបរទេស ។

ទី២- ការពិភាក្សាគ្នានៃតំណាងយោធា ដែលនឹងជជែកគ្នាអំពី

ក) អ្វីជាវត្ថុបំណងនៃការប្រជុំ ? គឺថា ការមិនធ្វើសកម្មភាពប្រមូលផ្តុំកងទ័ពឡើងវិញ ផ្ទុយទៅវិញពួកគេត្រូវ តែដកថយ ហើយនិងធ្វើឡើងនូវការសិក្សា :

1-កាលបរិច្ឆេទចុងក្រោយនៃការពន្យារពេលដកកងទ័ព ។

2-មធ្យោបាយដាក់ការចាត់ចែងមេបញ្ជាការវៀតមិញ សំរាប់ការអនុញ្ញាតរបស់គេធានាដល់កិច្ចសន្យាថា ពួក គេត្រូវបានប្រកាន់យកការជម្លៀសកងទ័ពរបស់ខ្លួន ។

3-ដូចម្តេចទៅចំពោះផ្លូវធានាជីវិត ឬការដែលរកឃើញផ្លូវដែលកងទ័ពទាំងឡាយអាចអនុវត្ត ដើម្បីចាកចេញ ពីកម្ពុជា ?

ខ) តើតំណាងមេបញ្ជាការនៃបក្សជម្លោះទាំងពីរនឹងសំរួលដូចម្តេច ? (គេត្រូវធ្វើការជួបប្រជុំមេបញ្ជាការនៃ កម្ពុជា និងវៀតមិញ)

គ) ការជួបប្រជុំនៃតំណាងមេបញ្ជាការទាំងពីរ និងត្រូវប្រារព្ធនៅទីណា ? (កន្លែងជួបគ្នា)

នៅក្នុងប្រទេសកម្ពុជាឯណោះវិញ នាខេត្តបាត់ដំបង ព្រឹកថ្ងៃទី២៩មិថុនា មានមហាបាតុកម្មកម្មមួយកើតឡើង ដែលមានបាតុករជាទាហាន បុគ្គលិក មន្ត្រីរាជការ គ្រូបង្រៀន សិស្ស ប្រជារាស្ត្រ សរុបប្រហែល ១២០០០នាក់ បានដង្ហែរក្បួនមកឈប់នៅចំពីមុខសាលាក្រុង និងកន្លែងសំខាន់ៗមួយចំនួនទៀត ដោយមានកាន់បដាជាច្រើន ព្រមជាមួយការស្រែកជយឃោសគាំទ្រដល់ព្រះមហាក្សត្រសីហនុ ដល់រាជរដ្ឋាភិបាល ដល់ប្រតិភូរាជរដ្ឋាភិបាលដែលកំពុងជាប់ចរចានៅហ្សឺណែវ ស្រែកបដិសេធថាគ្មានរដ្ឋាភិបាលណាមួយផ្សេងទៀតទេនៅកម្ពុជា ស្រែកថា ចក្រពត្តិវៀតមិញកំពុងតាំងទីដើម្បីបំផ្លិចបំផ្លាញនៅកម្ពុជា លទ្ធិកុំមុយនីស្តមិនមែនជាសាសនារបស់កម្ពុជា លទ្ធិកុំមុយនីស្តប្រឆាំងនឹងព្រះពុទ្ធសាសនា និងស្នើអោយពួកនេះចាកចេញពីកម្ពុជា ហើយបាតុករក៏បានស្រែកស្វាគមន៍ចំពោះប្រទេសថៃ ដែលបានទទួលអោយគណកម្មការនៃអង្គការសហប្រជាជាតិស្នាក់នៅ ក្នុងដំណើរបេសកកម្មស្វែងរកការពិតដល់ទីកន្លែងនៅប្រទេសកម្ពុជា ។

## ខ.៣- បញ្ហាការសិក្សាដំណោះស្រាយរួមមួយសំរាប់ប្រទេសទាំងបី

ដោយសារវត្តមាននៃកងទ័ពនិយ័ត និងអនិយ័តរបស់ខ្លួនមាននៅប្រទេសកម្ពុជា ក៏ដូចជាឡាវ ទើបលោក ផាម វ៉ាន់ដុង ព្យាយាមទាញហេតុផលបង្ហាញអង្គសន្និសីទអោយយល់ថា ស្ថានភាពនៃសង្គ្រាមនៅប្រទេសទាំងបី គឺវាដូចគ្នា វិបាកនៃប្រទេសមួយមានបច្ច័យទាក់ទងនឹងប្រទេសមួយទៀត ។ ហេតុនេះសន្និសីទត្រូវតែសិក្សាករណីនៃប្រទេសទាំងបីរួមគ្នាតែមួយ ដើម្បីកុំអោយខាត ឬបាត់បង់សម័យប្រជុំរបស់ខ្លួន ។

ចំណែកលោក ផន វិញ ផុលផុសក្នុងការតវ៉ាយ៉ាងដាច់អហង្ការ មិនអោយមានការសិក្សាដំណោះស្រាយរួមគ្នាសំរាប់កម្ពុជា-វៀតណាម-ឡាវ ។ ព្រោះ គាត់មានកាតព្វកិច្ចធ្វើអ្វីៗដើម្បីផលប្រយោជន៍របស់កម្ពុជា ។ តាំងពីពេលសន្និសីទហៀបនឹងបើក គណប្រតិភូខ្មែរបានទទួលសេចក្តីណែនាំពី លោក ស្មីតថា"កុំភ្លេចនិយាយ ថាកម្ពុជាបានឯករាជ្យហើយ" ។ នៅកម្ពុជាមានសក្តិកម្មមួយ គឺ ការលុកលុយរបស់កងឯកភាពវៀតមិញ តាមរយៈឈ្លើយសឹកជាច្រើននាក់ដែលរាជរដ្ឋាភិបាលកម្ពុជាចាប់បានក្នុងពេលធ្វើប្រតិបត្តិការសឹក ។ ទាំងនេះជាការខុសគ្នាស្រឡះពីប្រទេសវៀតណាមដែលមានការប្រឈមមុខគ្នារវាងកងទ័ពបារាំង និងកងទ័ពរំដោះជាតិ ។ ប្រតិភូរាជរដ្ឋាភិបាល តែងតែលើកយកពាក្យទាំងនេះមកនិយាយជាដរាបក្នុងការចរចា ។

បន្ទាប់មកលោក ស្មីត នៅថ្ងៃទី១៨ឧសភា បានទទូចសុំអោយមានការពិភាក្សាដោយឡែក សំរាប់កម្ពុជា និងឡាវ ផ្តាច់បញ្ហានៃប្រទេសទាំងពីរនេះ អោយដាច់ចេញពីយុទ្ធសាស្ត្ររួមរបស់វៀតមិញ ហើយអេដេនក៏យល់ស្របតាមចំណែកខាងកុំមុយនីស្តមានលោក ជូ ក៏បានជួយអារកាត់បញ្ហានេះ ថាត្រូវតែសិក្សាករណីប្រទេសទាំងបីផ្សេងពីគ្នា ។

## ខ.៤- ការដោះលែងអ្នកទោសសង្គ្រាម និងអ្នកជាប់ឃុំស៊ីវិល

ចំណុចនេះ យើងមិនឃើញមានការជជែកច្រើនទេ នៅក្នុងរង្វង់សន្និសីទ ដោយសារគ្រប់ភាគីជម្លោះសុទ្ធតែបានដាក់ស្នើនៅក្នុងគំរោងដំណោះស្រាយរបស់ខ្លួន ហើយជាទូទៅពួកគេសុទ្ធតែបានយល់ស្របគ្នា ។ ម្យ៉ាងទៀត វាជាចំណែកមួយនៃផែនការយោធា ដែលត្រូវបានគេពិភាក្សាដោយសំងាត់រវាងអ្នកតំណាងមេបញ្ជាការយោធាទ្វេភាគី ហើយយើងក៏មិនដែលបានឃើញឯកសារស្តីអំពីការពិភាក្សាទាំងនោះដែរ ។

## ១.៥- បញ្ហាទាក់ទងការនាំចូលបុគ្គលិកកងទ័ព សព្វាវុធ និងសំភារៈសឹកថ្មីៗចូលមកក្នុងប្រទេស

ដំបូង គឺគណប្រតិភូវៀតមិញ ដែលបានថ្លែងក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនកាលពីថ្ងៃទី១០ឧសភា ត្រង់ចំណុចទី៨(ខ) អំពីការបញ្ឈប់ជាស្ថាពររាល់ការនាំចូលកងកំលាំងថ្មីៗ បុគ្គលិកយោធាទាំងជើងគោក ជើងទឹក(សមុទ្រ) និងអាកាស អាវុធយុទ្ធភ័ណ្ឌគ្រប់ប្រភេទ ព្រមទាំងសំភារៈសឹកមកក្នុងឥណ្ឌូចិន ។

នៅក្នុងសន្និសីទថ្ងៃទី០៣មិថុនា លោក ផន បានថ្លែងអំពីការហាមប្រាមនាំអាវុធចូលឥណ្ឌូចិន ជាពិសេសកម្ពុជា ថា កម្ពុជាផ្ទាល់ត្រូវការអាវុធជាចាំបាច់សំរាប់ប្រើ ការពារសន្តិសុខ ។ ដើម្បីប្តូរយកសេរីភាពរបស់ខ្លួន កម្ពុជាគួរតែត្រូវបានទទួលអាវុធទាំងនេះ កម្ពុជាត្រៀមខ្លួនទទួលយកជាបន្ទាន់ នូវកិច្ចសន្យារារាំងការជ្រៀតចូលនៃកងទ័ពបរទេសមកក្នុងទឹកដីរបស់ខ្លួន ។ បើគេហាមឃាត់ការនាំអាវុធចូលមកកម្ពុជានោះ គឺផ្តល់ដល់កម្ពុជានូវការឈ្លានពានមួយ ប្រសើរជាងគេរារាំងការឈ្លានពានដោយខ្លួនឯង (Cambodge avait besoin d'armes pour le defense de sa securité, mais, ajouta-t-il, en echange de la liberté, qui lui serait donnée de recevoir ces armes, le Cambodge serait prêt à prendre l'engagement d'empêcher l'entrée de toute les troupes étrangères dans son territoire. Il souligna que si l'on interdisait l'entrée d'armes dans son pays, ce serait livrer le Cambodge à l'invasion. Il convient plutôt d'interdire l'invasion elle-même.) ។

បញ្ហានៅត្រង់ថា រដ្ឋាភិបាលកម្ពុជា ទើបទទួលបានអធិបតេយ្យភាពខាងយោធាពីបារាំងទាំងស្រុងនៅថ្ងៃទី០៩វិច្ឆិកា១៩៥៣ តាមរយៈសន្និសញ្ញាថ្ងៃទី១៧តុលា១៩៥៣ ។ ដូច្នេះ វិស័យកងទ័ពនៃខេមរភូមិន្ទពិតជានៅក្មេងខ្ចី មានការខ្វះខាតអាវុធយុទ្ធោបករណ៍ទំនើបៗ សំភារៈសឹក បច្ចេកទេស ហើយកងទ័ពជាតិមានសមត្ថភាពប្រយុទ្ធនៅខ្សោយនៅឡើយ ។ ប្រសិនបើ កម្ពុជារងនូវការឈ្លានពានពីបរទេសទៀតនោះ ពិតជាមិនអាចទប់ទល់សត្រូវបានទេ ។ វៀតមិញពិតជាបានដឹងច្បាស់អំពីបញ្ហានេះ ថាជាការមួយផ្ទុយស្រឡះពីប្រទេសខ្លួន នៅវៀតណាមខាងជើង ដែលបានទទួលជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ពីប្រទេសចិន ចាប់តាំងពីពេលគេផ្តើមធ្វើការតស៊ូប្រឆាំងបារាំង ។ ជំនួយទាំងនោះមាន សព្វាវុធគ្រាប់រំសេវ សំភារសឹកគ្រប់ប្រភេទ អ្នកបច្ចេកទេសយោធា ថ្នាំពេទ្យ មនោគមវិជ្ជា ជាដើម ។ ដូច្នេះ វៀតមិញអាចឈប់នាំចូលបរិក្ខារបំរើការអោយផ្នែកសឹកបាន ទើបគេលើកលក្ខខណ្ឌនេះឡើង ដើម្បីរាំងខ្ទប់សមត្ថភាពការពារខ្លួនរបស់ប្រទេសកម្ពុជា ឬមួយប្រទេសឡាវ ។

ចំណែកលោក សម សារី ថ្លែងជាសាធារណៈនៅថ្ងៃ០៩មិថុនាថា កម្ពុជាត្រូវការអាវុធជាចាំបាច់ សំរាប់ការពារអធិបតេយ្យភាពជាតិ បើគេមិនដោះស្រាយបញ្ហានេះទេ ហើយបើពិនិត្យឃើញថា លទ្ធផលចុងក្រោយនៃសន្និសីទធ្វើអោយខកចិត្តនោះ កម្ពុជាត្រៀមរៀបចំខ្លួនរួបរួមជាមួយលោកខាងលិច ជាពិសេសប្លុកយោធាអាមេរិក ដើម្បីការការពារឯករាជ្យ និងបូរណភាពដែនដីរបស់ខ្លួន ។

បន្ទាប់មកលោក ផនបានសង្កត់ធ្ងន់នៅថ្ងៃទី១៦មិថុនា អំពីឆន្ទៈរបស់រាជរដ្ឋាភិបាលខ្មែរ ក្នុងការប្រកាន់ខ្ជាប់មិនអោយមានកងទ័ព ឬមូលដ្ឋានសឹកបរទេសណាមួយតាំងនៅក្នុងទឹកដីរបស់ខ្លួន និងឆន្ទៈមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសដទៃ ។ ក៏ប៉ុន្តែ ទៅថ្ងៃអនាគតសុំកុំអោយមានការចាប់កំហុសប្រទេសកម្ពុជា ក្នុងការដែលប្រទេសនេះស្វែងរក

គ្រប់មធ្យោបាយ ដើម្បីការពារខ្លួនឯង នៅពេលដែលគេពុំបានផ្តល់យុត្តិធម៌អោយ ហើយនឹងពេលដែលគេធ្វើអ្វី១គ្រប់យ៉ាង ដើម្បីរារាំងប្រទេសនេះ មិនអោយរស់ក្នុងអព្យាក្រិតភាព សេរីភាព និងសន្តិភាព ។

បន្ទាប់មកទៀតលោក ជូ ថ្លែងតបទៅនឹងសំណើរបស់ផនថា ការទាក់ទិនបរិមាណ និងប្រភេទសព្វាវុធសំខាន់ៗសំរាប់ការពារខ្លួនអាចនឹងត្រូវបានគេយល់ព្រម ហើយគេនឹងកំណត់នៅក្នុងកម្មវត្ថុនៃការចរចាដាច់ដោយឡែកពីគ្នា ។

តាមសេចក្តីអធិប្បាយរបស់ផន ត្រង់ចំណុចទី៣ ផ្នែកខាងដើម នៅថ្ងៃទី១៨មិថុនា គឺដូចគ្នានឹងសំណើរបស់វៀតមិញដែរ ។ ក៏ប៉ុន្តែ ចំពោះបរិមាណ និងប្រភេទអាវុធសំខាន់ៗសំរាប់ការពារខ្លួន អាចនឹងត្រូវបានអោយនាំចូលដែលប្រព្រឹត្តទៅតាមកម្មវត្ថុនៃការចរចាគ្នាមួយដាច់ដោយឡែក ។

នៅក្នុងកិច្ចសន្ទនាជាមួយលោក ជូថ្ងៃទី១៤កក្កដា លោក ផនចង់បានការធានាថា មហាប្រទេសចិន នឹងមិនប៉ះពាល់ដល់ឯករាជ្យនៃប្រទេសណាមួយ ជាអាទិ៍ប្រទេសកម្ពុជា ។ ពេលនោះ លោក ជូ ក៏បានធានាផងដែរ អំពីអាវុធដែលទុកសំរាប់ធានាដល់ឯករាជ្យនៃប្រទេស ថាអាចនឹងត្រូវបញ្ចូលដោយគ្មានលក្ខខណ្ឌ( គ្មានដាក់កំណត់-គ្មានបន្ថយ) ។ ប៉ុន្តែត្រូវធ្វើអោយជឿថា នៅក្នុងរយៈពេលដ៏ខ្លី គេត្រូវបញ្ចូលអាវុធទៅក្នុងវិធានការណ៏ ដែលមានលក្ខខណ្ឌ ។

នៅក្នុងកិច្ចប្រជុំលើកទី៣០ ដែលប្រតិភូនីមួយៗមានតែតំណាងពីរនាក់ចូលរួម នៅថ្ងៃទី១៨កក្កដា លោក ជូបានស្នើទៅ អេដេនអោយផ្តល់នូវការធានាយ៉ាងមធ្យ័តម្តងទៀតអំពីប្រទេសកម្ពុជាថា នឹងគ្មានមូលដ្ឋាន យោធាសហរដ្ឋអាមេរិក ។ ពីព្រោះលោក ជូ ពិតជាដឹងយ៉ាងច្បាស់ថា សហរដ្ឋអាមេរិកមានមូលដ្ឋានយោធានៅកោះអូគីណាវ៉ា ហ្វីលីពីន ប៉ាគីស្ថាន និងកំពុងតែចូលមកដល់វៀតណាមខាងត្បូង ព្រមទាំងថៃឡង់ដ៏ ។ ហេតុនេះប្រសិនបើកម្ពុជា និងលាវធ្លាក់ទៅក្នុងប្លុកយោធារបស់អាមេរិកទៀតនោះ ផលវិបាកនឹងកាន់តែធ្ងន់ធ្ងរចំពោះចិន ដែលត្រូវប្រឈមមុខ គឺបានន័យថា សត្រូវនៅជុំវិញខ្លួន សូម្បីតែសហភាពសូវៀត និងវៀតណាម ។ ពេលនោះ លោក អេដេនបានអោយការធានា "ក្រៅផ្លូវការ" ទៅកាន់លោក ជូ ជាមួយនឹងសេចក្តីបញ្ជាក់ថា "ប្រទេសកម្ពុជា និងឡាវនឹងក្លាយទៅជាប្រទេសអព្យាក្រិត្យ ដែលនឹងការពារដោយប្រទេសបារាំង ក្នុងក្របខ័ណ្ឌនៃសហភាពបារាំង" ។

## ខ.៦- អំពីការបោះឆ្នោតជាសាកល

នៅក្នុងខ្លឹមសារនៃសេចក្តីថ្លែងការណ៏គណប្រតិភូវៀតមិញថ្ងៃទី១០ឧសភា ត្រង់ចំណុចទី៣ ស្នើអោយមានការរៀបចំការបោះឆ្នោតជាទូទៅដោយសេរី នៅក្នុងប្រទេសវៀតណាម កម្ពុជា និងប៉ាថេតឡាវ ក្នុងទស្សនៈបង្កើតរដ្ឋាភិបាលឯកភាពមួយនៅក្នុងប្រទេសទាំងបី ។ ក្រុមប្រឹក្សាសន្និសីទអំពាវនាវអោយតែងតាំងអ្នកតំណាងរដ្ឋាភិបាល នៃគណបក្សទាំងពីរនៅប្រទេសវៀតណាម កម្ពុជា និងប៉ាថេតឡាវ សំរាប់រៀបចំ និងដំណើរការបោះឆ្នោតជាទូទៅដោយសេរី ។ ក្រុមប្រឹក្សាសន្និសីទនេះនឹងនាំមកនូវរាល់របៀបចាត់ការ ដើម្បីធានាសេរីភាពនៃទង្វើរបស់គណបក្សទាំងឡាយ ក្រុមទាំងឡាយ និងអង្គការសង្គមអ្នកស្នេហាជាតិ ។ កិច្ចអន្តរាគមន៍នីមួយៗពីបរទេសនឹងមិនត្រូវបានអនុញ្ញាត ។ គណកម្មការក្នុងស្រុកនឹងត្រូវបង្កើតឡើង ដើម្បីត្រួតពិនិត្យការប្រុងប្រៀបរៀបចំ និងដំណើរការបោះឆ្នោត ។

បន្ទាប់មកលោក សឺន សាន បញ្ជាក់ត្រង់ចំណុចទី៣នៃសេចក្តីថ្លែងការណ៏ថ្ងៃទី១៤ឧសភារបស់លោកថា ការបោះឆ្នោតជាទូទៅហៅថា "សេរី" ធ្លាប់បានធ្វើរួចហើយនៅកម្ពុជា ហើយកម្ពុជានឹងអាចរៀបចំធ្វើការបោះឆ្នោតបែបនេះ

ម្តងទៀតបាន នៅពេលដែលកងទ័ពវៀតមិញបានដកចេញពីប្រទេស នៅពេលអសន្តិសុខ ដែលបង្កឡើងដោយពួកនេះបានវិនាសបាត់អស់ ។ កម្ពុជា មិនអនុញ្ញាតអោយមានការគ្រប់គ្រង និងត្រួតពិនិត្យតំបន់ទាំងឡាយ ដែលកំពុងកាន់កាប់ដោយភាគីនិមួយៗ តាមសំណើរបស់វៀតមិញបានឡើយ ។

ចំណែកលោក ផន ថ្លែងថា ចាប់តាំងពីមានសង្គ្រាមមកការបោះឆ្នោតនៅកម្ពុជា មានចំនួនបីលើករួចមកហើយ ដោយមានការចូលរួមពីអតីតខ្មែរឥស្សរៈផងដែរ ។ ប្រសិនបើ ខ្មែរឥស្សរៈវៀតមិញមានការតស៊ូ ដោយផ្អែកលើការគាំទ្ររបស់ប្រជាជនកម្ពុជា ដូចដែលខ្លួនបានអះអាងមែននោះ គេត្រូវតែមកបង្ហាញខ្លួនក្នុងការបោះឆ្នោត ហើយចាប់យកអំណាចដោយមិនបាច់បង្ហូរឈាមប្រជាជនឥតប្រយោជន៍ ។

## ខ.៧- អំពីគណកម្មការត្រួតពិនិត្យអន្តរជាតិ

គ្រប់ភាគីសុទ្ធសឹងស្នើអោយមានគណកម្មការអនុវត្តកិច្ចព្រមព្រៀង ។ ក៏ប៉ុន្តែ ខនេះត្រូវរអូសបន្លាយពេលពិភាក្សាគ្នាយ៉ាងយូរ ។ ដោយហេតុថា ភាគីនិមួយៗចង់បានតម្លាភាពនៃភារកិច្ច និងអព្យាក្រិតភាពរបស់គណកម្មការនេះប្រកបដោយកិច្ចធានាយ៉ាងមធ្យ័ត ។

អំពីសមាសភាពគណកម្មការនេះប្រតិភូខ្មែរ បានស្នើទៅអង្គសន្និសីទកាលពីថ្ងៃទី ៤មិថុនា ថាត្រូវជ្រើសរើសប្រទេសអព្យាក្រិត្យចំនួន៣ ពីក្នុងចំណោមប្រទេសចំនួន៧គឺ : ឥណ្ឌា ប៉ាគីស្ថាន ភូមា ហ្វីលីពីន ជប៉ុន កាណាដា និងអ៊ីតាលី ។ កម្ពុជា គឺជាបក្សព័ន្ធនៃការត្រួតពិនិត្យអន្តរជាតិ ដើម្បីអនុវត្តខសំខាន់ទាំងឡាយនៃកិច្ចព្រមព្រៀង ស្តីពីការបញ្ឈប់ប្រទូស្តរាយយោធា ។ សំរាប់កម្ពុជាការត្រួតពិនិត្យនេះ អាចជាការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។ ប៉ុន្តែក្នុងលក្ខខណ្ឌនៃស្ថានការណ៍ពិសេសរបស់ខ្លួន កម្ពុជាប្រាថ្នាអោយការត្រួតពិនិត្យនេះ ធ្វើដោយប្រជាជាតិ ដែលបានតែងតាំងដោយសន្និសីទទីក្រុងហ្សឺណែវ[៨] និងលើសំណើរបស់ខ្លួន ។ គណកម្មការយុទ្ធសន្តិភាពពិសេសមួយនៅកម្ពុជាមិនត្រូវមានគណកម្មការចំរុះពីរទេ គណកម្មការនេះ គឺត្រូវជាគណកម្មការត្រួតពិនិត្យតែមួយ ។

គណប្រតិភូសហភាពសូវៀតវិញ ចង់បានសមាជិក៤ប្រទេស ដែលមាន ឥណ្ឌា ប៉ាគីស្ថាន ប៉ូឡូញ និងឆេកូស្លូវ៉ាគី ដោយលើកហេតុផលថា ប្រទេសទាំងនេះធ្លាប់មានបទពិសោធន៍នៅប្រទេសកូរេ ។ គណកម្មការនេះអាចសំរេចកិច្ចការផ្សេងៗបាន លុះត្រាបានសម្លេងជាឯកច្ឆ័ន្ទ ហើយសមាជិកកុំមុយនីស្តមានសិទ្ធិបោះឆ្នោតជំទាស់(Véto)នៅក្នុងការប្រជុំសម្រេច ប្រសិនបើគេត្រូវធ្វើ ។ នៅពេលបន្ទាប់មក គេបានផ្លាស់ប្រទេសប៉ាគីស្ថានចេញពីសមាសភាពគណកម្មការរួចជំនួសដោយប្រទេសឥណ្ឌូនេស៊ី ហើយសន្និសីទយល់ព្រមលើក តំណាងនៃប្រទេសឥណ្ឌាអោយធ្វើជាប្រធាន ។ ក្នុងពេលជាមួយគ្នានោះ មានសំណើមួយទៀត គឺសមាសភាពនៃគណកម្មការមានតែបីប្រទេស គឺ ឥណ្ឌា( ក្នុងឋានៈជាប្រធាន

---

[៨] មូលហេតុ ដែលសន្និសីទមិនចង់អោយបុគ្គលិកនៃអង្គការសហប្រជាជាតិមានតួនាទីនៅក្នុងដំណោះស្រាយជម្លោះនៅឥណ្ឌូចិន ព្រោះតែប្រទេសកុំមុយនីស្តមួយចំនួនខ្លាចបាត់បង់ផលប្រយោជន៍របស់ខ្លួននៅឥណ្ឌូចិន ហើយទឡ្ហីករណ៍មួយទៀតគឺប្រតិភូភាគច្រើន មិនមែនជាសមាជិកនៃអង្គការនេះ ជាពិសេសប្រទេសចិន កម្ពុជា វៀតណាម និងឡាវ ។ ប៉ុន្តែ ការពិតវាគ្រាន់តែជាលេសមួយប៉ុណ្ណោះ ពីព្រោះ អង្គការសហប្រជាជាតិត្រូវបានគេហៅអោយជួយធ្វើអន្តរាគមន៍នៅប្រទេសកូរេ ដែលមិនមែនជាសមាជិករបស់ខ្លួនបាន ។

គណកម្មការអព្យាក្រិត្យ) ប៉ូឡូញ និងឥណ្ឌូនេស៊ី នេះបើតាមការពិភាក្សានៅថ្ងៃទី២២មិថុនា ។

ដោយសារនៅសម័យប្រជុំថ្ងៃបន្តបន្ទាប់មក អ្នកតំណាងមហាអំណាចបារាំង អង់គ្លេស និងចិន សហការគ្នាសំរុះសំរួលបដិមតិ ទើបគ្រប់ភាគីឈានដល់ការយល់ព្រមលើ សមាសភាពគណកម្មការត្រួតពិនិត្យអន្តរជាតិអព្យាក្រិត្យមួយ ដែលមានប្រទេសឥណ្ឌាជាប្រធាន ប្រទេសប៉ូឡូញ និងកាណាដាជាសមាជិក ។ ទាំងអស់គឺមានបីប្រទេស ដើម្បីជៀសវាងការខ្វែងគំនិតគ្នាក្នុងការអនុវត្តខយុទ្ធសន្តិភាព ហើយអាចធ្វើអោយការប្រជុំសម្រេចផ្សេងៗក្នុងរង្វង់គណកម្មការនេះ ភាគច្រើនបានទទួលជោគជ័យ ។ ចំណែកលក្ខន្តិកៈចែងអំពីអំណាច តួនាទី និងភារកិច្ចនៃគណកម្មការនេះ មានចែងក្នុងអត្ថបទកិច្ចព្រមព្រៀងចុងក្រោយ ។

## ខ.៨- បញ្ហាផ្សេងៗ

មធ្យោបាយជាច្រើន ដែលគណប្រតិភូនិមួយៗប្រកាន់យក មានការធ្វើសន្និសីទកាសែត ការណាត់ជួបពិភាក្សាគ្នាជាឯកជន ដែលទង្វើបែបនេះបានផលច្រើនជាងការពិភាក្សាក្នុងអង្គប្រជុំផ្លូវការ ។ ដូចជា លោក សម សារីសមាជិកគណប្រតិភូខ្មែរ បានធ្វើសន្និសីទកាសែត នៅថ្ងៃទី៩មិថុនា ដែលទុកដូចជាការគំរាមមួយចំពោះមហាអំណាចកុំមុយនីស្ត ។

ចំពោះការចរចាជាឯកជន ច្រើនតែប្រមុខប្រតិភូមហាអំណាច ជាអ្នករៀបចំឡើង ។ បន្ទាប់ពីគេឈានដល់ការព្រមព្រៀងធ្វើសម្បទានមួយចំនួនដល់គ្នាហើយ ទើបយកមកបង្ខំកូនអុករបស់ខ្លួនអោយទទួលយក ។ ដូចជា តាំងពីដំបូង លោក វីរធីរ បេដេល ស្មីត ប្រាប់លោក ផនអោយប្រកាន់ជំហរថា "កម្ពុជាបានទទួល ឯករាជ្យរួចហើយ" ។ លោកជួយល់ព្រមជាមួយលោក អេដេន មិនបញ្ចូលភាគីខ្មែរឥស្សរៈវៀតមិញ និងប៉ាថេតឡាវ ទៅក្នុងសម័យប្រជុំតាមសំណើរបស់វៀតមិញ ។ ការអញ្ជើញគណប្រតិភូខ្មែរ ឡាវ និងវៀតមិញទៅជួបគ្នាក្រៅផ្លូវការ ដើម្បីជជែកដេញដោលគ្នារកការពិត និងបំណងពិតដោយលោក ជូ អេនឡាយ ។

ក្រោយមក មានការទទួលស្គាល់ នូវឯករាជ្យនៃប្រទេសកម្ពុជាពីសំណាក់ប្រតិភូចិន ដែលជាហេតុធ្វើអោយប្រតិភូខ្មែរកាន់តែបានចិត្តទន្ទេញជាប់មាត់ថា "កម្ពុជាជាប្រទេសឯករាជ្យ" រហូតធ្វើអោយលោក ម៉ូឡូតូវ ចំអកអោយថា វាជាការមួយមានន័យសំខាន់ណាស់ ដែលប្រទេសចិនបានទទួលស្គាល់រាជរដ្ឋាភិបាលកម្ពុជា និងលាវ ពីព្រោះសូម្បីតែប្រទេសនៅអាស៊ីមួយចំនួនដូចជា ឥណ្ឌា ប៉ាគីស្ថាន ភូមា ឥណ្ឌូនេស៊ី ហ្វីលីពីន និងស្រីលង្កា ក៏ពុំបានទទួលស្គាល់រាជរដ្ឋាភិបាលរបស់សម្ដេច សីហនុផង ។ បន្ទាប់មកមានការទទួលស្គាល់នូវប្រិយភាព ដែលមិនអាចមានអ្នកណាប្រជែងបាននៅកម្ពុជារបស់សម្ដេច សីហនុ ពីសំណាក់លោក ផាម វ៉ាន់ដុងប្រធានប្រតិភូវៀតមិញ ។

ទោះបីការប្រជុំផ្លូវការមានរយៈពេលយូរ ហើយអ្នករៀបចំសន្និសីទបានទទួលលៀងភោជនាហារក្រោយពីការពិភាក្សាក៏ដោយ ក៏នៅក្នុងឱកាសដែលប្រតិភូនានាកំពុងហូបបាយនោះ ពួកគេមិនបានជួបគ្នា ជជែកគ្នាដោយសេរី និងមិត្តភាពឡើយ ។ ពោលគឺក្រុមប្រតិភូនិមួយៗ ទទួលទានដោយឡែកៗពីគ្នា ។ ជាការមួយផ្ទុយគ្នាទាំងស្រុងពីជំនួបជាឯកជន ។

## គ- កិច្ចព្រមព្រៀងថ្ងៃបញ្ចប់

ក្រោយពីមហាអំណាចចែកផ្លូវគ្នាទៅពិភាក្សានៅក្រុងប៉ារីសមួយរយៈ និងបានស្រុះស្រួលគ្នាជាសំងាត់រួចមក គេក៏ត្រឡប់មកបើកសន្និសីទវិញ ។ ក្រោយពីបញ្ជាក់ពីចំនុចព្រមព្រៀង និងមិនព្រមព្រៀងឡើងវិញដោយត្រួសៗមក សហប្រធានសន្និសីទលោក អេដេន និងម៉ូឡូតូវ បានកំនត់ពេលវេលាជួបប្រជុំគ្នាថ្ងៃចុងក្រោយ នៅរាត្រីថ្ងៃទី២០កក្កដា វេលាម៉ោង ៩ ដែលជាសម័យប្រជុំលើកទី៣១ ដើម្បីចុះហត្ថលេខាព្រមព្រៀងបញ្ចប់ ។

នៅថ្ងៃចុងបង្ហើយ អ្នកបើកឡានដឹកប្រតិភូខ្មែរវង្វេងផ្លូវនៅក្រុងហ្សឺណែវ ធ្វើអោយភាគីខ្មែរទៅដល់គេហដ្ឋានលោកអេដេន យឺតពេល២ម៉ោង ។ គណប្រតិភូទាំងអស់ រង់ចាំដោយក្តីអន្ទះសារ ក្នុងការចុះហត្ថលេខាលើអត្ថបទសន្និសញ្ញាចុងក្រោយមួយ ។ នៅពេលគណប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទៅដល់ សម័យប្រជុំចាប់ផ្តើមឡើង ។ ក្រោយពីពិនិត្យលើអត្ថបទព្រមព្រៀងសំរាប់ប្រទេសកម្ពុជារួច ស្រាប់តែលោក ទេព ផន មិនព្រមឆ្លើយស្របទៅនឹងអេដេន និងម៉ូឡូតូវ ដោយទាមទារអោយសន្និសីទកែប្រែអត្ថន័យនៃមាត្រាមួយចំនួនជាមុនសិន ពីព្រោះមាត្រាទាំងនោះ នឹងនាំអោយកម្ពុជាមានគ្រោះថ្នាក់ទៅថ្ងៃអនាគត ។ ពេលនោះ លោក ម៉ូឡូតូវបានក្រេវក្រោធឡើងស្ទើរតែទប់មិនបាន រួចទើបសម្រន់កំហឹង សម្រួមឥរិយាបថ ធ្វើជាអាជ្ញាកណ្តាលអារកាត់សេចក្តីក្នុងនាទីចុងក្រោយនេះ ។

ខ្លឹមសារមួយចំនួនដែលលោក ផន យល់ថានឹងមានគ្រោះថ្នាក់សម្រាប់អនាគតនៃប្រទេសកម្ពុជា និងបានស្នើសុំកែប្រែនោះ គឺ :

1- វៀតមិញ សុំអោយនាំអាវុធយុទ្ធភ័ណ្ឌ និងបុគ្គលិកយោធាចូលមកកម្ពុជា ដោយធ្វើនៅត្រង់កន្លែងខ្លះនៃប្រទេស ដែលគេកំរិតទុកមុន ដូចនៅប្រទេសឡាវ ។ កម្ពុជាបានចង់អោយការនាំចូលនេះ ធ្វើទៅនៅកន្លែងណាក៏ដោយនៃព្រំដែនរបស់ខ្លួន ។ ត្រង់នេះសន្និសីទបានយល់ព្រមតាមសំណូមខ្មែរ ទើបក្នុងសេចក្តីថ្លែងការណ៍ចំណុចទីបួន( អំពីកងទ័ពបរទេស) និង កិច្ចព្រមព្រៀងប្រការ៧ នៅវាក្យខ័ណ្ឌចុងក្រោយ គេមិនបានចង្អុលទុកនូវការកំណត់ព្រំដែនសំរាប់ប្រទេសកម្ពុជា ។

2- កិច្ចព្រមព្រៀងបង្ហើយ និងត្រង់ប្រការ៧ ចែងថា ប្រទេសកម្ពុជា មានប្រភេទជាប្រទេស"អព្យាក្រឹត្យ" ឥតជ្រៀតជ្រែកក្នុងកិច្ចការអន្តរជាតិណាមួយឡើយ ទោះជានៅពេលវេលាណាក៏ដោយ ។ ចំពោះរឿងនេះ កម្ពុជាសន្យាថានឹងមិនចូលក្នុងសម្ព័ន្ធកិច្ចយោធាណា ដែលមិនត្រឹមត្រូវតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិឡើយ ។ ប៉ុន្តែ ប្រតិភូខ្មែរទាមទារអោយមានសិទ្ធិដាក់មូលដ្ឋានទ័ពបរទេស នៅពេលណាដែលខ្លួនយល់ថាមានគ្រោះថ្នាក់ ។ ទោះបី ផាំ វ៉ាន់ដុងតវ៉ាប្រឆាំងយ៉ាងណាក៏ដោយ ក៏លោក ម៉ូឡូតូវព្រមកែមាត្រានេះអោយ ដែលធ្វើអោយប្រតិភូទាំងអស់ភ្ញាក់គ្រប់ៗគ្នា ។

3- លើបញ្ហានៃការដកថយចេញរបស់កងទ័ពវៀតមិញ និងការដកអាវុធចេញពីកងខ្មែរវៀតមិញ លោក ដុងស្នើអោយពួកខ្មែរ ដែលបានធ្វើសហប្រតិបត្តិការជាមួយវៀតមិញ នៅមានសិទ្ធិកាន់អាវុធរហូតដល់ពេលបោះឆ្នោតជាតិ (ត្រង់នេះ ផាម វ៉ាន់ដុងចង់អោយកម្ពុជាមានតំបន់អបគមន៍ និងមានសង្គ្រាមស៊ីវិលបន្តទៀត) ។ បន្ទាប់ពីការតវ៉ាប្រឆាំងយ៉ាងខ្លាំងពីប្រតិភូខ្មែរ វៀតមិញបែរជាស្នើអោយមានគណកម្មការចំរុះមួយ ដែលមានតំណាងរបស់រាជរដ្ឋាភិបាល និងតំណាងនៃរដ្ឋាភិបាលខ្មែរវៀតមិញរបស់ សឺង ង៉ុកមិញ ហើយគណកម្មការនេះនឹងដោះស្រាយបញ្ហានៃការបញ្ចូលកងខ្មែរវៀតមិញមកក្នុងសង្គមជាតិវិញ ចំណែកការសំរេចទាំងឡាយរបស់គណកម្មការចំរុះនេះ នឹងត្រូវត្រួត

ពិនិត្យដោយគណកម្មការអន្តរជាតិមួយខាងកិច្ចត្រួតត្រា ។ ដោយឥតរវល់នឹងប្រតិកម្មពេញដោយកំហឹងនៃពួកប្រតិភូវៀតមិញ ម៉ូឡូតូវបានអារកាត់ជាលើកបង្ហើយ ដោយទាត់ចោលរឿងទទួលស្គាល់រដ្ឋាភិបាលខ្មែរវៀតមិញរបស់លោក សឺង ង៉ុកមិញ ។

4- លោក ផន រំលឹកថា អង្គសន្និសីទបានបំភ្លេច"អនុស្សរណៈស្តីអំពីទឹកដីរបស់កម្ពុជានៅវៀតណាមខាងត្បូង" ដែលគណប្រតិភូខ្មែរ បានចែកជូនរាល់សមាជិកសន្និសីទក្នុងពេលពិភាក្សាកន្លងមក ។ ដោយសារព្រំដែនទឹកដីនៃកម្ពុជា និងវៀតណាមខាងត្បូងបច្ចុប្បន្ន បានកំនត់ឡើងដោយអំពើជាឯកតោភាគីរបស់បារាំង ទើបជាហេតុធ្វើអោយកម្ពុជារងនូវការបាត់បង់ដែនដីរបស់ខ្លួនមួយចំនួន ហើយនេះជាការចាំបាច់ សំរាប់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដើម្បីស្នើសុំអោយសន្និសីទជួយដោះស្រាយ ។

ពេលនោះ លោក អេដេន ឆ្លើយតបថា សន្និសីទទទួលយកសេចក្តីប្រកាសរបស់ប្រតិភូកម្ពុជា ប្រសិនបើវាមិនបានធ្វើអោយស្មុគស្មាញ ក្នុងការចុះក្នុងបញ្ជីឯកសារក្រោមអំណាចនៃសន្និសីទ ។ ហេតុផលស្តីអំពីបញ្ហានេះ គឺយ៉ាងធម្មតា ដែលលោកមិនអាចទទួលយកវាមកពិនិត្យជាថ្មីទៀតបានឡើយ ។ សន្និសីទ គ្មានសិទ្ធិ នឹងលើកយករឿងនេះមកនិយាយទេ ព្រោះវានឹងវិលត្រឡប់ទៅរកជំលោះពីបុព្វកាលមួយ ដែលទាក់ទងទៅលើគំនូរនៃព្រំប្រទល់រវាងប្រទេសកម្ពុជា និងវៀតណាមខាងត្បូង ។ ភ្លាមនោះដែរ ផាម វ៉ាន់ដុង ឡើងថ្លែងគាំទ្រទស្សនៈអេដេន ។

ដោយសារ គ្មានគណប្រតិភូដទៃទៀតជួយធ្វើអន្តរាគមន៍ ហើយលោក ម៉ូឡូតូវនិយាយដោយមិនសប្បាយចិត្តថា គណប្រតិភូខ្មែរគួរតែល្មមគ្រប់គ្រាន់ហើយ ព្រោះខ្លួនទាមទារបានច្រើនលើសប្រតិភូដទៃទៀត ទើបលោក ផនយល់ព្រមជាលើកបង្ហើយ ហើយគ្រប់គណប្រតិភូចាប់ផ្តើមសំដែងការចាប់អារម្មណ៍តាមរយៈស័ង្កថារៀង១ខ្លួន ។

ប្រទេសមហាអំណាចទាំងអស់សុទ្ធតែពេញចិត្តចំពោះលទ្ធផលនៃសន្និសីទ លើកលែងតែសហរដ្ឋអាមេរិកមួយប៉ុណ្ណោះ ដែលបានចាត់ទុកកិច្ចព្រមព្រៀងនេះថាជា"មហន្តរាយ" ដោយគេយល់ថា"ឥណ្ឌូចិននឹងធ្លាក់ទៅក្នុងដៃរបស់ពួកកុំមុយនីស្ត" ដែលជាគូរបដិបក្សរបស់ខ្លួន ។

សូមបញ្ជាក់ថា នៅលើកិច្ចព្រមព្រៀងសំរាប់កម្ពុជាចុះហត្ថលេខាដោយ ឧត្តមសេនីយ៍ ញឹក ជូឡុងតំណាងបញ្ជាការកងទ័ពជាតិខ្មែរ និងឧត្តមសេនីយ៍ តា កាងប៊ូ ជាតំណាងបញ្ជាការកងឯកភាពតស៊ូខ្មែរ និងបញ្ជាការកងទ័ពវៀតមិញ ដែលជាការប្លែកគ្នាពីកិច្ចព្រមព្រៀងសំរាប់ប្រទេសឡាវ និងវៀតណាម គឺកិច្ចព្រមព្រៀងចុះហត្ថលេខាដោយបញ្ជាការកងទ័ពបារាំង និងវៀតមិញ ។

អត្ថបទនៃកិច្ចព្រមព្រៀងថ្ងៃទី២១កក្កដា១៩៥៤នេះចែកចេញជាពីរផ្នែក គឺទី១ កិច្ចព្រមព្រៀងស្តីពីការបញ្ឈប់សង្គ្រាមនៅកម្ពុជា មានប្រាំជំពូក ដែលចែងអំពីគោលការណ៍ និងបែបបទនៃការប្រតិបត្តិការឈប់បាញ់, ការដកថយនៃកងទ័ព និងបុគ្គលិកទាហានបរទេសចេញពីដែនដីកម្ពុជា, អំពីការហាមនាំ កងទ័ពថ្មី បុគ្គលិកទាហាន សព្វាវុធ គ្រាប់រំសេវ និងមូលដ្ឋានសឹកចូលក្នុងប្រទេស ការដោះលែងឈ្លើយសឹក , អំពីគណកម្មការចំរុះ និងគណកម្មការអនុរក្សពិនិត្យត្រួតនៅកម្ពុជា ចុងក្រោយនិយាយអំពីការប្រតិបត្តិខព្រមព្រៀង ។ ខ្លឹមសារកិច្ចព្រមព្រៀងនេះមាន៣៣មាត្រា ។

ទី២ សេចក្តីថ្លែងការណ៍ចុងក្រោយរបស់ គណប្រតិភូនៃប្រជាជាតិទាំងប្រាំបួនក្នុងសន្និសីទទីក្រុងហ្សឺណែវ ស្តីពីបញ្ហានៃការកសាងសន្តិភាពឡើងវិញនៅឥណ្ឌូចិន មាន១៣ចំណុច គឺ អំពីការយល់ព្រមរបស់គណប្រតិភូទាំងអស់, អំពីឯករាជ្យនៃរដ្ឋនិមួយៗក្នុងរដ្ឋទាំងបី, អំពីការជ្រើសតាំងនៅប្រទេសកម្ពុជា និងឡាវក្នុងឆ្នាំ១៩៥៥, អំពីកងទ័ពបរទេស, អំពីសម្ព័ន្ធភាពខាងយោធា, អំពីខ្សែបន្ទាត់បែងចែកប្រទេសវៀតណាម ទុកជាខ្សែកាត់បណ្តោះអាសន្ន, អំពីការជ្រើសតាំងនៅក្នុងប្រទេសវៀតណាមក្នុងខែកក្កដា១៩៥៦, អំពីសេរីភាពនៃការតាំងលំនៅរបស់បុគ្គលនិមួយៗ, អំពីការលើកលែងទោស, អំពីការដកកងទ័ពបារាំងចេញ, អំពីប្រទេសបារាំងនឹងឯករាជ្យនៃប្រទេសទាំងបី, អំពីប្រជាជាតិទាំង៩នឹងឯករាជ្យ និងអំពីប្រជាជាតិទាំង៩នឹងគណកម្មការពិនិត្យត្រួត ។ ក្រៅពីនេះនៅមានសេចក្តីថ្លែងការណ៍ជាច្រើនទៀតដែលធ្វើឡើងដោយរដ្ឋនានានៅឥណ្ឌូចិន ស្របតាមឆន្ទៈចង់ស្ថាបនាសន្តិភាពនៅផ្ទៃក្នុងនៃប្រទេសរៀងៗខ្លួន ។

## ៣. សេចក្តីសន្និដ្ឋាន

សន្និសីទទីក្រុងហ្សឺណែវចាប់ពីថ្ងៃទី០៨ឧសភា ដល់២១កក្កដា ឆ្នាំ១៩៥៤ មិនមែនជាការដោះស្រាយបញ្ហាជម្លោះរវាងមហាអំណាចអាណានិគមបារាំង និងកម្ពុជានោះទេ ។ វា គឺជាការចរចាបញ្ចប់ការឈ្លានពានរបស់កងកំលាំងវៀតមិញ(វៀតណាមកុំមុយនីស្ត)នៅលើទឹកដីកម្ពុជា ក្រោយពីការលុកលុយរបស់ពួកគេ អស់រយៈពេលជាច្រើនឆ្នាំក្រោមលេសចូលមកជួយរៀបចំ ពង្រឹងកំលាំងតស៊ូរបស់ខ្មែរឥស្សរៈវៀតមិញ ដើម្បីច្បាំងតទល់នឹងបារាំង ទាមទារយកឯករាជ្យជាតិ និងក្នុងគោលបំណងប្រែក្លាយរូបភាពពីសហភាពឥណ្ឌូចិនបារាំង មកជាសហព័ន្ធឥណ្ឌូចិនរបស់វៀតណាមតាមគោលដៅរបស់មេបដិវត្តន៍កុំមុយនីស្តវៀតណាម ឈ្មោះហូ ជីមិញ។

លទ្ធផលនៃសន្និសីទនេះ ជាការបំពេញបន្ថែមពីលើឯករាជ្យខ្មែរឆ្នាំ១៩៥៣ និងជាជោគជ័យដ៏ធំធេងមួយទៀតរបស់កម្ពុជា ក្នុងឱកាសដ៏ចែងចាំងមួយនៅលើឆាកអន្តរជាតិ ។ យ៉ាងហោចណាស់ គណប្រតិភូខ្មែរ បានខិតខំការពារកម្ពុជា មិនអោយមានវាសនាដូចនៅប្រទេសវៀតណាម ដែលត្រូវសន្និសីទសម្រេចបែងចែកជាពីរ គឺវៀតណាមខាងជើង(កុំមុយនីស្តវៀតមិញ) និងវៀតណាមខាងត្បូង(របបមហាក្សត្របៅ ដាយ) ហើយនៅប្រទេសឡាវ កងកំលាំងតស៊ូប៉ាថេតឡាវ ត្រូវបានសន្និសីទអនុញ្ញាតអោយប្រមូលផ្តុំនៅក្នុងតំបន់កាន់កាប់របស់ខ្លួន គឺខេត្តពីរនាទិសឥសាននៃប្រទេសរហូតដល់មានការបោះឆ្នោតជាទូទៅនៅឆ្នាំ១៩៥៥ ។ បន្ទាប់មក ភ្លើងសង្គ្រាមស៊ីវិលបានបន្តឆេះនៅក្នុងប្រទេសទាំងពីរនេះរហូតមក ដោយសារតែដំណោះស្រាយបែបនេះ ។ ចំណែក កម្ពុជាមានសន្តិភាពគ្រប់គ្រាន់សំរាប់ការអភិវឌ្ឍន៍ជាតិ ។

ម្យ៉ាងទៀត កិច្ចព្រមព្រៀងនេះ ជារបត់ប្រវត្តិសាស្ត្រដ៏សំខាន់មួយនៃប្រទេសកម្ពុជា សំរាប់មាគ៌ានយោបាយបង្រួបបង្រួមជាតិ និងការបរទេស ។

## ឯកសារពិគ្រោះ

~~~~~~~~~~~~~

1- AKP(Agence Khmere de Presse) du 21 Mai 1954,No.1157,pp.VI-VII.
2- AKP du 22 Mai 1954,No.1158,pp.$C_{3\text{-}9}$.
~~~~~~~~~~~~~

3- AKP du 23 Mai 1954,No.1159,pp.$C_{2-3}$.
4- AKP du 24 Mai 1954,No.1160,pp.$C_{3-4}$.
5- AKP du 30 Mai 1954,No.1166,pp.$C_{1-4}$.
6- AKP du 03 Juin 1954,No.1170,pp.VIII-IX.
7- AKP du 05 Juin 1954,No.1172,pp.VIII-X.
8- AKP du 09 Juin 1954,No.1176,p.II.
9- AKP du 11 Juin 1954,No.1178,pp.III-XII.
10- AKP du 23 Juin 1954,No.1190,p.VIII.
11- AKP du 02 Juillet 1954,No.1199,p.$C_1$.
12- AKP du 04 Juillet 1954,No.1201,pp.XII-XIII.
13- AKP du 05 Juillet 1954,No.1202,p.$C_1$.
14- AKP du 16 Juillet 1954,No.1213,pp.I-IV.
15- AKP du 18 Juillet 1954,No.1215,pp.X-XI.
16- AKP du 20 Juillet 1954,No.1217,pp.X-XI.
17- AKP du 21 Juillet 1954,No.1218,p.I.
18- Ben Kienan, dans Cambodge Histoire et enjeux, Paris,pp.99-102.
19- Conférence de Genève sur l'Indochine, 08 Mai à 21 Juillet 1954, 657 pages.
20- Foreign Affairs Ministry of People's republic of Kampuchea, "Chinese Rulers' Crime against Kampuchea" Phnom Penh,April 1984,pp.16-32.
21- ង៉ែត ហៀន "កិច្ចព្រមព្រៀងហ្សឺណែវ ដើម្បីរំលត់ភ្លើងសង្គ្រាមឥណ្ឌូចិន បែរទៅជាដុតភ្លើងសង្គ្រាមឥណ្ឌូចិនទៅវិញ" ភ្នំពេញ ១៩៧១ ទំព័រ ១-៣៨ ។
22- ចាន់ ដារ៉ា "កម្ពុជា និងសហព័ន្ធឥណ្ឌូចិន" ម៉ុងរ៉េអាល់ កាណាដា មេសា១៩៨៣ ទំព័រ ១១៧-១២០ ។
23- បិន ឃៀនិន "តើប៉ុល ពតចូលកាន់អំណាចបែបណា?" SPK ភ្នំពេញ ១៩៩២ ទំព័រ ១៥១-១៦១ ។
24- ប៊ុណ្ណ ចាន់ម៉ុល "ចរិតខ្មែរ" ភ្នំពេញ ១៩៧៣ ទំព័រ ៣០-៤៣ ។
25- ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសំរាប់ប្រទេសកម្ពុជា ភ្នំពេញ គ្មានឆ្នាំបោះពុម្ព ទំព័រ២០
26- មិញ នាត្រី "សេចក្តីថ្លែងការណ៍ និងកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ស្តីអំពីការបញ្ឈប់សង្គ្រាមក្នុងឥណ្ឌូចិន ចំពោះប្រទេសកម្ពុជា" ភ្នំពេញ ឧសភា១៩៥៥ ២៨ទំព័រ ។
27- សឹន សាន "បទសម្ភាសជាមួយក្រុមសាស្ត្រាចារ្យប្រវត្តិវិទ្យា នៅព្រឹកថ្ងៃទី២៤និង២៧មិថុនា១៩៩៨" ភ្នំពេញ ។
28- ហ៊ិន ស៊ីថាន "នរណាជាឃាដករ" ស៊ីអាថិល សហរដ្ឋអាមេរិក ១៩៨៦ ទំព័រ ៣៦-៤៥ ។
29- ហ៊ុន សែន "១៣ទសវត្សនៃដំណើរកម្ពុជា" ភ្នំពេញ ១៩៨៩ ទំព័រ ៣៥-៧៤ ។
30- ឡាច សារីត "ឯកសារសំងាត់មន្ទីរប៉ង់តាហ្គោន" ភ្នំពេញ កក្កដា ១៩៧២ ទំព័រ ៤០-៥០ ។